សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Free

## មាតិការឿង

Issue 183 Aug 24th - Sept 04th, 2015

១-ពិធីប្រណាំងទូកនៅឡូវែល........................០៣
២-បទសម្ភាសន៍ជាមួយលោក រាល ខេមរិន្ទ..........០៤
៣-ហាងផ្ញើលុយ "ស្តុំរ៩៩"ត្រូវចោរប្លន់..............០៥
៤-លោក តិច កិម បើកយុទ្ធនាការឃោសនា.........១៤
៥-ខ្យងស្មោរជ្រលក់ទឹកត្រី...................................១៧
៦-ទំនប់រំលិច និងប្រវត្តិ កសាងជួរចត់......................១៨
៧-ចិត្តគំនិតជនទុច្ចរិត និងចិតគំនិតជនសុចរិត................១៩
៨-និយាយពីអ្នកក្រ និងមាន.................................២០

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# ដំណើរការកសាងសំណុំរឿង ដើម្បីនាំខ្លួន ហ៊ុន សែន ទៅកាត់ទោសនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ

**"Cambodian abroad filed against Hun Sen to the International Criminal Court"**



គ្រួសារ មាជ សុវណ្ណារ៉ា ទេព វណ្ណី រីឆាត រ៉ូជើស៍

**កាសែតខ្មែរប៉ុស្ដិ៍**

**ទីក្រុងឡូវែលៈ** កាលពីថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៥ មេធាវី រីឆាត រ៉ូជើស៍ បានជួបសំណេះសំណាលជាមួយបងប្អូនខ្មែរ-អាមេរិកនៅទីក្រុងឡូវែល ដើម្បីបង្ហាញជូននូវដំណើរការកសាងសំណុំរឿង ដើម្បីនាំខ្លួន ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់ខ្មែរមួយចំនួនទៀត ទៅកាត់ទោសនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ (ឬ ហៅកាត់ថា អាយស៊ីស៊ី)។ **តទៅទំព័រទី ០៦**

បទវិភាគ "Go Back to School 2015"

## បវេសនកាល២០១៥មកដល់



ពិន សំខុន

**ដោយ ពិន សំខុន**

**ឡូវែល ៖** ឆ្នាំនេះបើនិយាយពីរដូវត្រជាក់ គឺត្រជាក់ខ្លាំងណាស់ តែបើនិយាយពីរដូវក្តៅវិញ ក៏ក្តៅខ្លាំងណាស់ដែរ ក្រុមកសិករច្បាស់ជាញញឹមញញែម ពីព្រោះធាតុអាកាសរបៀបនេះ វាត្រូវប៉ាន់នឹងដំណាំដាំដុះណាស់ ដូច្នេះកសិករកំពុងផ្តើមទទួលផលកសិកម្មពីធាតុអាកាសប្រសើរនឹងពិបច្ចេក




ទេសខ្ពស់របស់គេហើយ សីហានេះ រហូតដល់ខែតុលាខាងមុខ។ ស្របគ្នានឹងបវេសនកាលមកដល់ នាដើមខែកញ្ញានេះ កូនស្រីប្រុសត្រូវមានករណីយកិច្ចត្រៀមខ្លួនត្រឡប់ទៅសាលារៀនវិញ បន្តការសិក្សាបន្ថែមទៀត ឬក៏ទើបនឹងបានចូលរៀន... ចំណែកឯមាតាបិតា ឬអនាព្យាបាលក៏មានករណីយកិច្ចក្នុងការទទួលខុសត្រូវពីជោគជ័យ ឬក៏បរាជ័យនៃការសិក្សារបស់កូនផងដែរ ដូច្នេះនៅមុន១០ថ្ងៃមុនថ្ងៃចូលរៀនម្នាក់ៗត្រូវដឹងខ្លួនថា **តទៅទំព័រទី ០៨**






# CENTURY PHARMACY & OPTICAL

937 Gorham St | ALL MAJOR INSURANCES ACCEPTED | Tel: 978-455-6554

យើងជាឱសថស្ថានមួយដែលអាចផ្តល់ភាពជឿជាក់ដល់គ្រួសារលោកអ្នក




យើងខ្ញុំសូមជូនពរមហាប្រសើរដល់លោកអ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

## 937 Gorham St Lowell, MA, 01852

# ពិធីប្រណាំងទូកនៅឡូវែល

# 19th. Annual Lowell Southeast Asian Water Festival





**ដោយ ពិន សំខុន**

**ឡូវែល:** កីឡាករខាងអុំទូកជាពួក ៥ ក្រុម បានបើកការប្រកួតនៅលើទន្លេ"មីរីម៉ាក"មុនកន្លែងទំនប់ទឹកធ្លាក់ឡូវែល កាលពីថ្ងៃសៅរ៍ ទី១៥សីហាឆ្នាំ២០១៥នេះ នៅចំពោះមុខសាធារណជនប្រមាណ៤។ ៥ម៉ឺននាក់ដែលមកគ្រប់ទិសទីមើលបុណ្យអុំទូកពិធីដែលមានឈ្មោះថា "បុណ្យអុំទូកអាស៊ីអគ្នេយ៍"។

ពិធីបុណ្យនេះ ឥឡូវបានក្លាយទៅជាពិធីដែលប្រមូលបុំជនអាស៊ីដ៏ច្រើនជាងគេទាំងអស់នាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកនេះទៅហើយ។ ទូកបែបបូរាណ២គ្រឿងធ្វើនៅប្រទេសឡាវចំណុះ១៥-១៦នាក់ បានត្រូវដាក់ឱ្យអុំប្រណាំងប្រកួតគ្នា២ក្រុមម្តង។ រហូតដល់បានលទ្ធផលជាចុងបញ្ចប់ដែលក្នុងនោះ មានក្រុមស្ត្រី១ក្រុមផងដែរ។

ការពិតទៅភ្ញៀវដែលមកកំសាន្តពិធីបុណ្យអុំទូកថ្ងៃនោះ នាំគ្នាពពាក់ពពូនគ្នាជាគ្រួសារតែមួយដើម្បីភ្លក់ម្ហូបអាហារ ឡាវ.ថៃ.ខ្មែរ.ភូមាដែលដាក់តាំងយ៉ាងឈ្យុយឆ្ងាញ់នៅតាមតូបតម្រៀបគ្នាយ៉ាងវែង នាមាត់ទន្លេ"មេរីម៉ាក់"។ នេះជាលើកទី២ហើយ ក្នុងមួយឆ្នាំដែលម្ហូបអាស៊ីមានមុខមាត់មកតាំងទីក្នុងពិធីដែលមានភ្ញៀវរាប់ម៉ឺននាក់មកកំសាន្តនៅឡូវែល។ កាលពីខែ មិថុនាមុននេះ ក្នុងពិធីបុណ្យ "Lowell folk Festival" ម្ហូបអាស៊ីមកពីហ្វីលីពីន.ឡាវ.ឥណ្ឌា មានប្រជាប្រិយភាពជាងគេ។ ឆ្នាំនេះយើងមិនបានឃើញចិននឹងវៀតណាមចូលរួមទេ។

នៅលើឆាកដែលជាចំណុចកណ្តាលសម្រាប់ផ្សព្វផ្សាយពីដំណើរការណ៏នៃពិធីបុណ្យអុំទូក កូវិត.គ្លា.នារីខាងឡាវ នឹងសូបិនជាពិធីកររួមបានណែនាំសិល្បៈ។ វប្បធម៌របស់ប្រទេសនៃអាស៊ីអគ្នេយ៍មាន ភ្លេង. ចម្រៀង. របាំខ្មែរ. ឡាវ. ភូមា ហើយឆ្នាំនេះ គុណភាពប្រសើរនៃការសម្តែងគ្រប់ក្រុមមានក្រុមសមាមអង្គរ ក្រុមរបាំឡាវ នឹងភូមា រីឯក្រុមភ្លេងមាន "Black Diamond -4 Shadow... "ចេញមកសម្តែងកំដរភ្ញៀវរហូតដល់ម៉ោង៤រសៀល។ នៅពេលទូក កំពុងអុំយ៉ាងព្យាយាម ដើម្បីជ័យជំនះតែរៀង១ខ្លួន...ក្រុមនារីក្លាហានបានទទួលជ័យជំនះខ្លះដែរ ធ្វើឱ្យសាធារណជនច្រឡំថានារីជាសភាវល្វតល្វៃមិនអាចយកឈ្នះលើក្រុមបុរសណាមួយទេ តែផ្ទុយទៅវិញ នារីក្លាហានបានទទួលជោគជ័យ រហូតឈ្នះទាំងក្រុម "Warriors" ដែលជាជ័យលាភីឆ្នាំមុនផង...នេះក៏ដោយសារតែការប្រឹងប្រែងស្រុះគ្នា... រីឯនៅលើគោកឯនោះវិញ អ្នកលក់ម្ហូបចំណីបំរើភ្ញៀវយ៉ាងញាប់ដៃរាប់លុយស្ទើរតែមិនទាន់។ ឆ្នាំនេះបុកល្ហុងឡាវ។ ទឹកអំពៅ ហើយនឹងសាច់អាំងច្រកាក់ហាក់មានប្រជាប្រិយភាពជាងម្ហូបណាទាំងអស់។ នៅមាន

**តទៅទំព័រទី ០៩**

















# បទសម្ភាសន៍ជាមួយលោក រាល ខេមរិន្ទ តំណាងរាស្ត្រខ្មែរ

## Interview with Real Khemrin Cambodian MP.

**ខ្មែរផុស ស.រ.អា**

នៅពេលធ្វើទស្សនកិច្ចនៅឡូវែលថ្ងៃទី១៤ សីហា កន្លងទៅលោក រាល ខេនរិន្ទ តំណាងរាស្ត្រមណ្ឌលស្វាយរៀង បានផ្ដល់បទសម្ភាសន៍មួយដល់ខ្មែរផុសស.រ.អាស្ដីពីការចោទប្រកាន់ថ្មីៗពីគណកម្មការប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាលដឹកនាំដោយលោក ឱម យិនទៀង ដែលជាមន្ត្រីជំនិតរបស់លោក ហ៊ុន សែន ។ ការចោទប្រកាន់នោះបានបំពងសម្លេងថា លោក រាល ខេមរិន្ទ បានធ្វើការរៃអង្គាសមួយបានប្រាក់៥ម៉ឺនដុល្លា ដើម្បីនាំប្រជាពលរដ្ឋ២៥០០នាក់ ទៅកាន់តំបន់ព្រំប្រទល់ដែននាខេត្តស្វាយរៀង ហើយប្រាក់នោះ បានត្រូវលោក រាល ខេមរិន្ទ គៃបន្លំយកបន្ទាប់ពីបាននាំប្រជាពលរដ្ឋទៅពិនិត្យព្រំដែនដោយផ្ទាល់រួចមក។



លោក រាល ខេមរិន្ទ ថតនៅក្នុងខ្មែរឡូវែល

**ខ្មែរផុសស.រ.អា:** សូមស្វាគមន៍លោក រាល ខេមរិន្ទ នៅឡូវែល...ភារកិច្ចនាំរាស្ត្រទៅពិនិត្យព្រំដែននេះ លោកមិនបានធ្វើដោយលុយរដ្ឋាភិបាលទេ តើមានរឿងហេតុអ្វីក៏គណកម្មការប្រឆាំងអំពើពុករលួយចោទប្រកាន់លោកពីរឿងពុករលួយហើយឱ្យលោកទៅឆ្លើយ?

**រាល ខេមរិន្ទ:** គណកម្មការលោក ឱម យិនទៀងមិនដឹងបានទិន្នន័យពីណាមកទេ ថាមានបណ្ដឹងថា ខ្ញុំបានទទួលលុយ១ម៉ឺន៥ពាន់មួយថាមានមួយទៀត២ម៉ឺនមួយទៀត២ម៉ឺន...

**ខ្មែរផុស ស.រ.អា:** តើលុយនោះរកបានមកពីណាខ្លះ?

**រាល ខេមរិន្ទ :** បានពីបងប្អូនខ្មែរយើងនៅអាមេរិក និងបងប្អូនខ្មែរនៅក្នុងស្រុក...ពីអាមេរិកគេផ្ញើរមកឱ្យបាន១ម៉ឺន៥ពាន់ ហើយលុយឯទៀតៗបានជាង៥ពាន់ទៀត ទាំងអស់បានជាង២ម៉ឺន...បន្តិចបន្តួច

**ខ្មែរផុសស.រ.អា:** តើមានអ្នកដឹងរឿងពីការមកដល់នៃលុយទាំងអស់នោះទេ?

**រាល ខេមរិន្ទ:** បាទ! គឺម្ចាស់លុយដែលគេផ្ញើរមកតាម"វេស្ទើនយូញោណ" នឹងតាម "ម៉ូនីក្រាម" ដូច្នេះមិនមានជាលុយលាក់បាំងអីទេ

**ខ្មែរផុសស.រ.អា.:** ដូច្នេះតើលោកមានសិទ្ធនឹងមិនឆ្លើយបានដែរឬទេ?

**រាល ខេមរិន្ទ :** បើខ្ញុំមិនឆ្លើយទៅលោក ឱម យិនទៀង ក៏បានដែរ! តែគ្មានអីនឹងលាក់ទេ! ហើយបើលោក ឱម យិនទៀង ចង់បានចម្លើយច្បាស់លាស់សុំឱ្យឈ្មោះអ្នកចោទប្រកាន់មកខ្ញុំ ហើយថាខ្ញុំបានទទួលលុយចំនួនដ៏ច្រើននោះរបៀបណា? យកល្អ លោក យិនទៀង គួរផ្តោតអារម្មណ៍ទៅលើអំពើពុករលួយដ៏ស្អុះស្អាយក្នុងរដ្ឋាភិបាលវិញ ទើបប្រសើរជាជាងមករករឿងលុយកាក់ដែលប្រជាពលរដ្ឋគេចាយដើម្បីរកភាពយុត្តិធមិការពារបូរណភាពទឹកដីដោយខ្លួនគេជាឯកជននោះ...

**ខ្មែរផុសស.រ.អា :** តើលោកចង់ថា រឿងនេះជារឿងនយោបាយ ដើម្បីចំណេញដល់ការបោះឆ្នោតនៅថ្ងៃមុខ តើមែនឬទេ?

**រាល ខេមរិន្ទ :** នេះវាច្បាស់ណាស់ហើយ ! នៅពេលដែលគណបក្សសង្គ្រោះជាតិកំពុងតែមានការផុសផុលទទួលការគាំទ្រពីប្រជាពលរដ្ឋទង្វើនេះគឺធ្វើដើម្បីបំបាក់មុខ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយជាប្រាកដ... ជាពិសេសខ្លួនខ្ញុំកំពុងធ្វើការជូនជាតិមួយដែលប្រជាជាតិផ្ដល់ការគាំទ្រជាអ្នកស្នេហាជាតិ គឺគេចង់ទាញទម្លាក់កេត្យានុភាពកុំឱ្យយើងធ្វើការជូនជាតិបាន។

**ខ្មែរផុសស.រ.អា :** លោកនិយាយពីអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ តើលោកយល់យ៉ាងណាពីការបែកបាក់គ្នានៃអ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅសហរដ្ឋអាមេរិកនេះ? តើនឹងមានផលប៉ះពាល់ដល់គណបក្សសង្គ្រោះជាតិនៅកម្ពុជាដែរឬទេ?

**រាល ខេមរិន្ទ :** ប្រជាពលរដ្ឋម្នាក់ៗនាប្រទេសសេរីនេះតែងមានយោបល់ប្លែកៗគ្នាជួនការក៏ខ្វែងគ្នានេះជាសិទ្ធសេរីភាពដែលម្នាក់ៗទទួលបាននៅទីនេះ តែទាំងអស់គ្នាមិនបានបញ្ឈប់ការគាំទ្រដល់គណបក្សសង្គ្រោះជាតិនៅឯកម្ពុជាទេ ដូច្នេះខ្ញុំយល់ថា មិនមានប៉ះពាល់អ្វីធំដុំដល់ការបោះឆ្នោតខាងមុខនៅកម្ពុជាទេ ។

**ខ្មែរផុសស.រ.អា :** សូមអរគុណ លោក រាល ខេមរិន្ទ ៕



# ហាងផ្ញើលុយ"ស្ទ័រ៩៩" ត្រូវចោរប្លន់

## Convenient store 99 has been robbed

**ដោយ ខ្មែរផុសស.រ.អា**



លោក គិម សេង

**ឡូវែល:** ប្រមាណជិតម៉ោង៩យប់ នៃថ្ងៃពុធទី១៩ ចោរ២រូបបានហក់ចូលមកសង្គ្រប់ម្ចាស់ហាងខ្មែរ ឈ្មោះ គីម សេង ដែលពេលរៀបបិទទ្វារ ហើយនៅតែម្នាក់ឯងក្នុងហាងផ្ញើរលុយទៅស្រុកខ្មែរដ៏ល្បីឈ្មោះមួយឈ្មោះ"99Store" នៅផ្លូវ "លីបើធី"លេខ១៨០ ពួកវាយកលុយបានប្រមាណជា១ម៉ឺនដុល្លា ជាលុយដែលភ្ញៀវផ្ញើរទៅក្រុមគ្រួសារគេនាក្រៅប្រទេស។ មួយប៉ព្រិចភ្នែក ក្រុមចោរដែលគេសន្និដ្ឋានថា ជាជនស្បែកខ្មៅនាំលុយរត់យ៉ាងលឿនចេញទៅក្រោមការដេញបាញ់របស់ គីម សេង ចំនួន២គ្រាប់តែមិនបានឱ្យត្រូវរបួសនរណាម្នាក់ទេ។






បងស្រី គីម សេង និយាយថា មុនពេលកើតហេតុបន្តិចប៉ូលីសបានឃើញមានជនគួរឱ្យសង្ស័យស្បែកពាក់ខ្មៅដើរក្រឡឹងហាងនោះដែរ... រីឯក្នុងហាងប្រពន្ធនឹងកូនធំៗរបស់ គីម សេង បានត្រូវដេញឱ្យឡើងទៅងូតទឹកមុនអស់ ហើយថ្ងៃនេះទៀត ក៏ភ្លេចយកលុយចេញពីប្រអប់ទៅទុកទៀត ដែលជាហេតុនៅសល់លុយច្រើនក្នុងថតតុចោរវាចាំមើលហើយដូចជាដឹងថា មានឱកាសដ៏ល្អនេះ ក៏ហក់ចូលមកប្លន់។ បងស្រីបន្តថា ប៉ូលីសបានចេញធ្វើអន្តរាគមន៍យ៉ាងឆាប់រហ័ស ហើយចាប់បានជនសង្ស័យម្នាក់នៅឆ្ងាយបន្តិច តែចៃដន្យអី នាប៉ុន្មានយប់នេះ ភ្លើងដាច់ងងឹតឈឹង នាខាងម្ខាងផ្លូវឯណោះ ។

គិម សេង បានមកបើកហាងលក់របស់របរប្រើប្រាស់ប្រចាំថ្ងៃនេះ១៧ឆ្នាំហើយ សព្វថ្ងៃហាងនេះត្រូវប៉ាន់ណាស់ ខ្មែរផុសតែងតែសួរនាំពីសុវត្ថិភាពពីហាងដែលបើកយប់ជ្រៅជាងគេមួយនេះ នៅពេលទៅទិញខតទូរស័ព្ទ ឬក៏ទៅផ្ញើរលុយម្តងៗ ពីព្រោះស្ថិតនៅឆ្ងាយពីប្រជុំពាណិជ្ជកម្មបន្តិចហើយមិនសម្បូរពន្លឺភ្លើងដងគោមផង តែ គីម សេង តែងតែបង្ហាញពីភាពជឿជាក់លើសន្តិសុខហាងខ្លួនជានិច្ចរហូតមកដល់ពេលនេះ។

គិម សេង នឹងគ្រួសារមានសំណាងណាស់ ដោយពុំមាននរណារងគ្រោះថ្នាក់ទេ។ ឡូវែលដែលធ្លាប់ល្បីឈ្មោះពីមុនថា ជាក្រុងសម្បូរក្លេងពេលនេះបានស្បើយច្រើនណាស់ ហើយតែសេចក្តីរាយការណ៍ពីការជួញដូរគ្រឿងញៀននៅតែមានជារឿយៗនៅឡើយដែរ ដូច្នេះឱ្យពុំទាន់ គួរឱ្យជឿជាក់បាននៅឡើយទេ ។

អ្នកស្រីម្ចាស់ហាងហុងកុងនៅមិនឆ្ងាយពីហាងកើតហេតុគាត់បិទហាងនៅម៉ោង៧កន្លះល្ងាចគាត់និយាយថា ធ្វើការរវល់ខ្លាំងពេកមិនបានគិតដល់រឿងសន្តិសុខខ្លួនឯងទេ តែគាត់មិនហ៊ាននៅយប់ពេកទេ ។ នារីម្នាក់នៅហាង "ខេម៉ាខិត" មិនហ៊ានឆ្លើយពិបញ្ហាសុវត្ថិភាពខ្លួនពីព្រោះខ្លួនមិនមែនជាម្ចាស់ហាងទេ។ ហាងផ្សេងៗទៀតនៅកណ្តាលក្រុងម្ចាស់ហាងគាតថា ម៉ោង៧យប់ គាត់ហត់ណាស់ហើយដុច្នេះ គាត់បិតព្រោះលែងចង់បានលុយទៀតហើយ...៕



ម្ចាស់ហាងហុងកុង

LOWELL

សមាគមបាល់ទាត់យុវជននៅឡូវែល

Lowell Youth Soccer Association

Fall Registration ចុះឈ្មោះសម្រាប់រដូវរងា
Teams are available for នៅសល់កន្លែងទំនេរ

Ages 3-11 Recreation League អាយុ ៣-១១ឆ្នាំ ក្រុមហាត់ទាត់បាល់

9-14 Travel League - អាយុ ៩-១៤ ឆ្នាំ ចាប់ផ្តើមប្រកួត

* Limited positions are available - Boys and Girls Under-10 - - Under-14
កំណត់កន្លែងដែលនៅសល់ -ក្មេងស្រី និងក្មេងប្រុសអាយុតិចជាង១០ឆ្នាំ -អាយុតិចជាង១៤ឆ្នាំ

Register On-line at:
lowellsoccer.com
978-918-0460

តមកពីទំព័រទី ០១

## ដំណើរការកសាងសំណុំរឿង នាំខ្លួន...

នៅចំពោះមុខបងប្អូនខ្មែរប្រមាណ៣០០នាក់ លោក រីឆាត រ៉ូជើស៍ បានគូសបញ្ជាក់អំពីភាពវិជ្ជមាននៃដំណើរការប្រមូលភ័ស្តុតាង ដើម្បីបង្ហាញព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ព្រះរាជអាជ្ញានឹងសម្រេចចាត់ការស៊ើបអង្កេតបឋមលើករណីបណ្តេញប្រជាពលរដ្ឋខ្មែរដោយបង្ខំចេញពីលំនៅដ្ឋាន និងការរឹបអូសដីធ្លី ស្រែចម្ការរបស់ពួកគាត់។



រីឆាត រ៉ូជើស៍ ជួបសហគមន៍ខ្មែរនៅឡូវែល

ក្នុងបណ្តឹងដែលលោក រីឆាត រ៉ូជើស៍ ដាក់ពាក្យប្តឹងទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពាក់ព័ន្ធនឹងមនុស្សបីក្រុមសំខាន់ៗ:

១-លោក ហ៊ុន សែន និង មន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលកម្ពុជា

២-មន្ត្រីជាន់ខ្ពស់ក្នុងជួរកងទ័ព និងនគរបាលជាតិ

៣-អ្នកជំនួញធំៗ

បទល្មើសដែលគាត់ដាក់ប្តឹង គឺពាក់ព័ន្ធនឹងការជម្លៀសប្រជាពលរដ្ឋដោយបង្ខំដែលជាធាតុផ្សំនៃបទល្មើសមួយក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ អ្នកដែលដាក់ពាក្យប្តឹងមានចំនួន១១នាក់ ដែលដំណាងឱ្យជនរងគ្រោះដោយការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំចំនួនប្រហែល ៤ សែននាក់។

បន្ទាប់ពីព្រះរាជអាជ្ញាចាប់ផ្តើមស៊ើបអង្កេតបឋមរួចមក រយៈពេលប្រហែល ៦ ខែ ទៅ ២ ឆ្នាំ តុលាការព្រហ្មទណ្ឌអន្តរជាតិចេញដីកាចាប់ខ្លួនលោក ហ៊ុន សែន និង មន្ត្រីជាន់ខ្ពស់ផ្សេងទៀត។

កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ នៅផ្លូម៉ូណា រដ្ឋកាលីហ្វ័រញ៉ា លោក រីឆាត រ៉ូជើស៍ បានចូលខ្លួនទៅធ្វើជាសាក្សី ដើម្បីបំភ្លឺចំពោះមុខសវនាការរបស់សភាអាមេរិកផ្នែកកិច្ចការបរទេសស្តីពីសិទ្ធិដីធ្លី និងការអភិវឌ្ឍនៅតំបន់អាស៊ីអាគ្នេយ៍។ សវនាការនេះ ត្រូវបានរៀបចំឡើងដោយអនុគណៈកម្មាធិការផ្នែកអាស៊ី និង ប៉ាស៊ីហ្វិក។ ក្នុងសវនាការនោះមានអ្នកចូលរួមប្រហែល ១០០០នាក់ ក្នុងនោះមានបងប្អូនខ្មែរចូលរួមយ៉ាងច្រើនលើសលុប។

ការធ្វើសក្ខីកម្មនៅក្នុងសវនាការសភាអាមេរិកនេះ បានផ្តល់ឱកាសឱ្យលោក រីឆាត រ៉ូជើស៍ បង្ហាញភ័ស្តុតាងអំពីការរំលោភបំពានសិទ្ធិមនុស្ស ការសម្លាប់មនុស្ស និងការធ្វើបាបប្រជាពលរដ្ឋខ្លួនឯងរបស់លោក ហ៊ុន សែន និង មន្ត្រីជាន់ខ្ពស់ដទៃទៀតនៅក្នុងជួរគណៈបក្សកាន់អំណាចសព្វថ្ងៃ។ សក្ខីកម្មនេះ ជួយគាំទ្រ និងពន្លឿននីតិវិធីរបស់ព្រះរាជអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីចាត់ការលើបណ្តឹងដែលលោក រីឆាត រ៉ូជើស៍ ដាក់ប្តឹងតំណាងឱ្យប្រជាពលរដ្ឋខ្មែរ។



រីឆាត រ៉ូជើស៍ ជួបសហគមន៍ខ្មែរនៅឡុងប៊ិច






នៅក្នុងសវនាការកាលពីថ្ងៃសុក្រកន្លងទៅនេះ យើងឃើញមានវត្តមានតំណាងអ្នកភូមិបឹងកក់ គឺលោកស្រី ទេព វន្នី និងក្រុមគ្រួសាររបស់សកម្មជនគណៈបក្សសង្គ្រោះជាតិលោក មាជ សុវណ្ណារ៉ា ផងដែរ។

តុលាការព្រហ្មទណ្ឌអន្តរជាតិជាតុលាការឯករាជ្យ និងអចិន្ត្រៃយ៍ មានយុត្តាធិការផ្តន្ទាទោសមេដឹកនាំណាដែលប្រព្រឹត្តអំពើអមនុស្សធម៌ប្រឆាំងប្រជាជនខ្លួនឯង៕



# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



### Blisterpack Packaging

### Friendly Consultations

### Compounded Medications

### Easy Transfers

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។

ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**
**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**
**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**
**មានផ្តល់ជូនម្សៅថ្នាំលាយ**
**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**






Cristina គ្រីស្ទីណាៈ
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Pahim លោកប៉ាហ៊ុម:
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឍមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តា ព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Dary ដារី:
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបបាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kelly ខែលលី:
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្ត្ររដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Daniela ដានីញ៉ែលឡា:
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញ៉ែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Kassandraកាសាន់ដ្រា:
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡូឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

## តមកទំព័រទី ០១ បរិវេសនកាល២០១៥មកដល់

តើអាត្មាអញ់ត្រូវធ្វើអ្វីខ្លះ នាពេលនេះ? ផ្លូវទៅសាលារៀនឆ្នាំនេះនឹងពោរពេញដោយសេចក្តីសង្ឃឹមដោយភាពរីករាយច្បាស់ជាដូចគ្នានឹងរដូវនៃឆ្នាំនេះដែរហើយ ។

អត្ថបទនេះ យើងចង់ផ្តោតទៅលើការពិគ្រោះជាមួយមាតាបីតា នឹងអណាព្យាបាលដែលឃ្លាតចាកពីស្រុកកំណើតមកពុំបាននាំយកចំណេះមើលថែរទាំការសិក្សារបស់កូនពីស្រុកកំណើតមកជាមួយទេ ធ្លាប់តែម្យ៉ាងគត់ គឺនាំកូនទៅប្រគល់ឱ្យសាលារៀន ហើយប្រាប់គ្រូថា "ស្បែកនឹងឆ្អឹងប្រគល់ជូនលោកគ្រូ ឬអ្នកគ្រូសូមទុកតែភ្នែកឱ្យខ្ញុំវិញបានហើយ" បានសេចក្តីថា អនុញ្ញាតឱ្យគ្រូបង្រៀនដាក់ទណ្ឌកម្មដល់រូបរាងកាយកូនខ្លួនបានលើកលែងតែភ្នែកតែខ្វាក់ហើយ មើលមិនជាទេ។ នៅស្រុកយើងគេថាជាគុណសម្បត្តិតែនៅទីនេះ ជាកំហុសធ្ងន់ធ្ងរណាស់ ពីព្រោះវិធីអប់រំកុមារនឹងយុវជនមិនប្រើហិង្សាទេ ទោះជានៅសាលារៀន ឬក៏នៅផ្ទះក៏ដោយ។ នា៣០ឆ្នាំចុងក្រោយនេះ មាតាបីតាខ្មែរបានប្រឈមមុខនឹងការអប់រំកូនប្រុសស្រីអោយបានស្របតាមច្បាប់អាមេរិកាំងបានយ៉ាងលំបាក ហើយបានធ្វើអោយកូនចៅខូចខាតអនាគតមួយចំនួនទៀតផង។

ទ្រឹស្តីសម័យខ្លះៗ-គេថា "មានតែការសសើរលើកទឹកចិត្តទេ ដែលបង្កើតការរៀនសូត្រ" ហើយគេប្រើទ្រឹស្តីនេះនៅសាលានៅផ្ទះ ក៏ដូចជានៅក្នុងគ្រួសារដែរ ហើយអ្វីគេបង្ហាត់កូនចៅ "ឱ្យធ្វើអ្វីដោយចិត្តចង់" មិនអាចបង្ខំបានទេ។ នៅមុនអាយុ១៦ឆ្នាំ កុមារ ឬយុវជននឹងត្រូវបាន មាតាបីតាអណាព្យាបាល ឬគ្រូបង្រៀនជាអ្នកបង្ហាត់បង្ហាញ តែឪពុកម្តាយ ឬអណាព្យាបាលនៅតែជាអ្នកសម្រេចនៅឡើយ ក៏ប៉ុន្តែពីអាយុ១៦ឡើងទៅយុវជនអាចមានសិទ្ធសម្រេចដោយខ្លួនឯងមួយចំនួន ដូចជាទៅរកការងារធ្វើជ្រើសរើសយកមុខវិជ្ជាដែលខ្លួនស្រឡាញ់ ទោះជានៅក្នុងបន្ទុកនៅឡើយក៏ដោយ។ ពីអាយុ១៨ឆ្នាំឡើងទៅមាតាបីតាអណាព្យាបាលលែងទទួលខុសត្រូវលើសេចក្តីសម្រេចចិត្តនឹងទង្វើរបស់កូនទៀតហើយ។

**នៅសាលារៀនកូន** -ឆ្នាំនេះក្រៅតែពីទៅទិញសៀវភៅខោអាវថ្មីអោយកូនទៅរៀនឪពុកម្តាយ ឬអណាព្យាបាលត្រូវគិតថាខ្លួនមានភារកិច្ចមើលកិច្ចការតាមដានសាលារៀនអោយផ្តល់ការសិក្សាអោយកូនអោយបានប្រសើរបំផុតគឺបើកូនរៀនចុះខ្សោយត្រូវតែសួរលោកគ្រូអ្នកគ្រូថាហេតុអ្វីបានជាកូនខ្ញុំចុះខ្សោយ? នេះជាសិទ្ធរបស់ទោះជាមានចំណេះតិចតួចក៏អាចជួយកូនអោយទទួលអនាគតល្អបានដែរ។ ក្រៅពីមានគ្រូនាយកសាលាលោកអ្នកត្រូវដឹងទៀតថា លោកអ្នកនៅមាន "កុងសីល័រ"នៅសាលាមានគណកម្មការសាលារៀនដែលលោកបោះឆ្នោតអោយនៅខែ



វិច្ឆិកាខាងមុខនេះ ជាជំនួយនៅខាងលោកអ្នកនឹងជួយគាំទ្រជាមួយគ្នាអោយកូននឹងរៀនបានយ៉ាងប្រសើរ។ ឪពុកម្តាយត្រូវរកឱកាសឱ្យបានយ៉ាងហោចណាស់១ខែម្តងទៅជួបគ្រូ ឬនាយកសាលាជាមួយកូនជាការបង្ហាញការគាំទ្រដល់ការសិក្សារបស់កូនលោកអ្នកនឹងឃើញការសិក្សារបស់កូនកែរប្រែជាប្រសើរជាមិនខានឡើយ។

**នៅផ្ទះ** -គួរមានកន្លែងដេក តុសរសេរទូរដាក់តវ៉ាន់ខោអាវដោយឡែកពីអ្នកឯទៀតដែលនៅផ្ទះជាមួយ។ បើគ្មានបន្ទប់ជាឯកជនឱ្យកូនម្នាក់មួយបន្ទប់ទេ គេគួរមានវិន័យក្នុងផ្ទះមួយមិនទទួលភ្ញៀវនៅថ្ងៃកូនរៀនមិនបើកទូរទស្សន៍ចាក់ភ្លេង ឬចាក់វិទ្យុ រំខានដល់ការរៀនសូត្រកូនទេ។ ពេលបាយគួរជុំគ្នាហោចណាស់ក៏ពេលល្ងាច ដើម្បីសួរនាំជាគ្រួសារផង នឹងចង់ដឹងពិការវិវឌ្ឍន៍នៃការរៀនសូត្រផង។ ក្លិនម្ហូប ឬកន្លែងមិនស្អាត ឬខោអាវមិនស្អាត វាក៏ជាការរំខានដល់ការរៀនរបស់កូនដែរ។ ត្រូវមើលឱ្យឃើញនូវការធ្វើបានល្អរបស់កូន ដើម្បីសំដែងការកោតសសើរ រីឯការធ្វើខុសឆ្គងត្រូវធ្វើការណែនាំមិនមែនវាយទេ។ ការចេះណែនាំធ្វើឱ្យចរិកកូនស្លូតបូត រីករាយ ចេះលេងជាមួយមិត្រវាបាន ។

**ទម្លាប់ជាប្រចាំ** -វាជាការចំណេញពេលនឹងមានប្រយោជនិខ្លាំងណាស់ បើយើងបង្កើតទម្លាប់ "របស់មួយកន្លែងវាមួយ" បានបង្កើត "ពេលមួយធ្វើអ្វីមួយ" ដូចជាពេលចូលដេកពេលហាត់ប្រាណ ពេលបាយ.. ...ទម្លាប់រៀបចំខ្លួន ទៅរៀនឱ្យទាន់ពេល...ទម្លាប់គួរសមជាមួយម្តាយឪពុក មាមីង មនុស្សស្គាល់គ្នា។

នេះគ្រាន់តែរំលឹកទ្រួស១ពីឱកាសចូលរៀន តើយើងគួរគិតពីអ្វី? តែប៉ុណ្ណោះការនិយាយពីជំនាញជាឪពុកម្តាយ ខ្មែរ អាមេរិកាំង លោកអ្នកអានប្រាកដជាមានបទពិសោធន៍ខ្ពស់ប៉ុន្មាន១០ឆ្នាំចុងនេះ ដែលប្រព័ន្ធផ្សព្វផ្សាយបញ្ជូនព័ត៌មានទូលំទូលាយដល់លោកអ្នកមិនឈប់ឈរ។ ដូច្នេះសូមជូនពរឱ្យលោកអ្នកប្រកបដោយជោគជ័យក្នុងការអប់រំកូនចៅ៕







តមកទំព័រទី ០៣

# ពិធីប្រណាំងទូកនៅឡូវែល

តូបលក់ដើមឈើបណ្តុះតូបតាំងគំនូរលាបពណ៌នៃយុវនារីខ្មែរស្រស់ស្អាតដែលនឹងសម្តែងការប្រឡងបវរកញ្ញានៅខែក្រោយនេះ។ ក្រៅពីនោះ ក៏មានតូបក្រុមជនំុសាសនាគ្រីស្ត ។ តូបសម្រាប់ព្រះពុទ្ធ មានឡាវ មានខ្មែរ មានណេប៉ាល់ ដែលផ្សព្វផ្សាយព្រះធម៌ជូនពរសេរីសួស្តីប្រាថ្នាចិត្តសទ្ធាសប្បុរសធម៌នៃអ្នកដើរកាត់...វត្តខ្មែរឡូវែលមានតាំងទូកងនៅដីគោកលំអដោយបដិមាករប៉ុនបាតដៃពណ៌សរាប់រយរូបដាក់លក់តម្លៃ១០០ដុល្លាក្នុងព្រះពុទ្ធបដិមាករមួយ ហើយវត្តនេះគ្រោងនឹងលក់ឱ្យបាន៨៤០០០ ក្នុងគម្រោងដ៏ធំមួយដែលសាធារណជនមិនច្បាស់ក្នុងចិត្តថា បានទទួលការអនុញ្ញាតិរួចហើយ។

ម៉ោងពារសៀលលទ្ធផលខ្លះៗបានចេញមកទូកវត្តត្រៃរតនារាមបានចំណាត់ថ្នាក់លេខ៣។ នៅសល់ទូក២ទៀតដែលកំពុងប្រកួតគ្នាយកចំណាត់ថ្នាក់លេខ១។ គឺទូក ប៉ាយ៉ាណាក់ ប្រកួតនឹងទូក "ញូអិនគ្លិន" នៅវេលាម៉ោង៤រសៀល។

ថ្ងៃសៅរ៍នេះ មេឃស្រឡះល្អណាស់ កំដៅឡើងលើស៨០ទៅហើយ យូរៗមានភ្លៀងធ្លាក់រោយបន្តិចបន្តួចគ្រាន់ត្រជាក់ដីបន្តិចដែរ។ គេសន្និដ្ឋានថាមានប្រជាជនចូលរួមប្រមាណ៤ទៅ៥ម៉ឺននាក់ ភាគច្រើនជាសហគមន៍ខ្មែរ ធ្វើឱ្យអ្នកមានតូបលក់របស់ប្រមាណជិត១០០តូប ញញឹមញញែមបិទមាត់មិនជិត អាចលក់ដូរ ឬបង្ហាញផលិតផលបានរហូតដល់ល្ងាច ។ ចរាចរផ្លូវ "ផទូកិត" នៃមាត់ទន្លេមានរថយន្តច្រើនណាស់ខុសសព្វមួយដង តែមិនស្ទះទេ ដោយគេបើកចំណតឡានសំរាប់ចតរាប់ពាន់ឡានធ្វើឱ្យ "វត្តឡាវ" ដែលដេញថ្លៃបានទទួលផលចំណេញយ៉ាងគាប់ចិត្ត រីឯម្ចាស់ដីនៅក្បែរៗ ក៏បើកឱ្យចតឡានយកឈ្នួលបានពី១៥ទៅ២០ដុល្លាដូចគ្នាដែរ។ ក្រុមប៉ូលីសនឹងក្រុមជំនួយបន្ទាន់លើទឹកនឹងលើគោគនៅប្រចាំការណ៏រហូតដល់ចប់បានរក្សាសន្តិសុខរក្សាចរាចរបានប្រសើរដោយមិនមានសៅហ្មងអ្វីបន្តិចឡើយ។

មន្ត្រីសាលាក្រុងឡូវែលមាន រីដា មើស៊ុ - សាមារា - កូរិ បាឡិនជ័រនឹងមន្ត្រីដំណាងរដ្ឋ រ៉ាឌីម៉ម បានមកសម្តែងការកោតសសើរដល់គណកម្មការរៀបចំពិធីបុណ្យអុំទូកដែលបានផ្តល់ភាពអធឹក

**តទៅទំព័រទី ១២**





















# សាលាថែទាំកុមារឡូវែល

LOWELL DAY NURSERY ASSOCIATION

119 HALL STREET
LOWELL, MASS.01854
**978-454-5981**

- កំពុងបើកទទួលសិស្សានុសិស្សកុមារ អាយុ១៥ខែ រហូតដល់២ឆ្នាំ៩ខែ
- សាលាមុនថ្នាក់មតេយ្យ
- មានបុគ្គលិកប្រកបគរុកោសល្យល្អ
- ជាសាលាល្អចំណាត់ថ្នាក់ប្រចាំឆ្នាំ

- OPENINGS AVAILABLE! TODDLERS -15 MONTHS THRU 2YEARS 9 MONTHS
- PRESCHOOL AND KINDERGARTEN
- GREAT CURRICULUM WITH SEASONED STAFF
- NATIONAL DIRECTOR OF THE YEAR

www.lowelldaynursery.com
or Like us on Facebook – Lowell Day Nursery Association









# Clemente Park Chiropractic

Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851
**(978) 937-1492**

**Treatments**

- Neck Pain
- Back Pain
- Lower Back Pain

- ឈឺ-ក
- ឈឺខ្នង
- ឈឺចង្កេះ-ខ្នង

- Automobile Injuries
- Personal Injuries
- Work Related Injuries

- គ្រោះថ្នាក់រថយន្ត
- រង់របួស
- របួសនៅកន្លែងធ្វើការ

WE ARE EXPANDING!
យើងនឹងបើកកន្លែងថ្មីមួយទៀត!

New Location in Lynn Opening in October!
383 Chestnut St. Lynn, MA 01904

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក កឹម សុខា និង លោក ស ខេង ជួបគ្នានៅសភា ដើម្បីពិភាក្សាបញ្ហានយោបាយ

**ដោយ ម៉ិច ដារ៉ា** | **August 11, 2015**

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង លោក កឹម សុខា អនុប្រធានគណបក្សប្រឆាំង បានជួបគ្នានៅរដ្ឋសភាកាលពីម្សិលមិញ ដើម្បីពិភាក្សាអំពីបញ្ហាដាក់ពន្ធនាគារសកម្មជនគណបក្សសង្គ្រោះជាតិចំនួន១៤រូបកាលពីពេលថ្មីៗនេះពាក់ព័ន្ធ "កុបកម្ម" នៅទីលានប្រជាធិបតេយ្យមួយសប្តាហ៍មុនពេលមានកិច្ចព្រមព្រៀងនយោបាយថ្ងៃ២២ កក្កដា កាលពីឆ្នាំមុន។

នៅក្នុងសេចក្តីសម្រេចភ្លាមៗកាលពីខែមុន សកម្មជនគណបក្សសង្គ្រោះជាតិចំនួន១១រូបត្រូវបានតុលាការសម្រេចឱ្យជាប់ពិរុទ្ធភាពពីបទកុបកម្មពាក់ព័ន្ធការតវ៉ាកាលពីថ្ងៃទី១៥ ខែកក្កដា ដើម្បីបើកទីលានប្រជាធិបតេយ្យឡើងវិញបណ្តាលឱ្យផ្ទុះអំពើហិង្សា ហើយសកម្មជនគណបក្សសង្គ្រោះជាតិបីរូបទៀតត្រូវបានចាប់ខ្លួននៅខែនេះបន្ទាប់ពីមានការអំពាវនាវពីសំណាក់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំង បានស្ថិតនៅអឺរ៉ុប និងសហរដ្ឋអាមេរិក ចាប់តាំងពីថ្ងៃដែលសកម្មជនទាំង១១រូបត្រូវបានតុលាការសម្រេចផ្តន្ទាទោសកាលពីថ្ងៃទី២១ ខែកក្កដា មកម្ល៉េះ ហើយលោក កឹម សុខា បានដឹកនាំយុទ្ធនាការរបស់គណបក្សប្រឆាំងដើម្បីឱ្យមានការដោះលែងសកម្មជនទាំងនេះ។

ជំនួបកាលពីម្សិលមិញរវាងលោក ស ខេង និងលោក កឹម សុខា បានធ្វើឡើងដោយបិទទ្វារ ហើយមេដឹកនាំទាំងពីរដែលញញឹមបិទមាត់មិនជិតនៅពេលដើរចេញមកខាងក្រៅវិញនោះ បានបដិសេធមិនថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មានទេ ដោយចាត់តាំងឱ្យអ្នកនាំពាក្យជាអ្នកថ្លែងជំនួស។

លោក សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃដែលតំណាងឱ្យលោក ស ខេង មានប្រសាសន៍ថា?មេដឹកនាំទាំងពីបានពិភាក្សាគ្នាលើបញ្ហាជាច្រើន ក្នុងនោះរួមមានទាំងសកម្មជនទាំងនេះផង ទោះបីជាអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានលើកឡើងកាលពីថ្ងៃអាទិត្យថា ការពិភាក្សាបែបនេះនឹងប៉ះពាល់ដល់ឯករាជភាពរបស់តុលាការក៏ដោយ។

លោកលើកឡើងបន្ថែមទៀតថា "ពាក់ព័ន្ធការចាប់ខ្លួនអ្នកដែលប្រព្រឹត្តបទល្មើស នោះគឺជានីតិវិធីច្បាប់។ ការពិភាក្សារបស់គណបក្សទាំងពីរ ធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ទៅដល់នីតិវិធីច្បាប់នោះទេ។ យើងខិតខំរកមធ្យោបាយដើម្បីជួយជាយោបល់ជួយជាគំនិតគ្នាទៅវិញទៅមក ប៉ុន្តែទោះជាជួយជាយោបល់ជួយជាគំនិតយ៉ាងណាក៏ដោយក៏ការជួយយោបល់ និងគំនិតទាំងនោះមិនប៉ះពាល់ដល់នីតិវិធីច្បាប់មិនប៉ះពាល់ទៅដល់សមត្ថកិច្ចរបស់ស្ថាប័នតុលាការនោះទេ"។

នៅពេលសុំឱ្យបញ្ជាក់ថា តើយោបល់បែបនេះអាចពាក់ព័ន្ធអ្វីខ្លះនោះលោកសក់សេដ្ឋាបានមានប្រសាសន៍ថា ចាំបាច់ត្រូវគោរពតាមនីតិវិធីច្បាប់ឱ្យបានត្រឹមត្រូវ ឬជួយឱ្យសកម្មជនគណបក្សសង្គ្រោះជាតិទទួលបានមេធាវី។ តាមពិតសកម្មជនទាំង១១រូបដែលត្រូវបានតុលាការចោទប្រកាន់ពីបទ"កុបកម្ម" និងបីរូបទៀតដែលត្រូវបានចាប់ខ្លួននៅខែនេះសុទ្ធតែមានមេធាវីរួចទៅហើយ។

លោក អេង ឆៃអ៊ាង តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលតំណាងលោក កឹម សុខា បានថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មានថា គណបក្សប្រឆាំងពេញចិត្តនឹងលទ្ធផលនៃការពិភាក្សានេះ ហើយគណបក្សទាំងពីរនឹងទុកឱ្យនីតិវិធីច្បាប់ពាក់ព័ន្ធសកម្មជនទាំងនេះបន្តដំណើរការទៅមុខ។

លោកបានមានប្រសាសន៍ដោយមិនលម្អិតថា "សម្រាប់បញ្ហានេះ យើងបានពិភាក្សាគ្នាជាច្រើន ហើយចុងបញ្ចប់ថ្នាក់ដឹកនាំនៃគណបក្សទាំងពីរបានព្រមព្រៀងគ្នាដូចអ្វីដែលលោក សក់ សេដ្ឋា បានលើកឡើង ហើយយើងនឹងប្រើប្រាស់នីតិវិធីច្បាប់ដើម្បីដោះស្រាយបញ្ហានេះ"។

**តទៅទំព័រទី១០**

# Parties Discuss Activists' Convictions, NGO Law

**BY MECH DARA | AUGUST 11, 2015**

Interior Minister SarKheng and deputy opposition leader KemSokha met at the National Assembly on Monday to discuss the recent jailing of 14 CNRP activists over the "insurrection" at Freedom Park a week before last year's July 22 political deal.

In a sudden decision last month, 11 CNRP activists were found guilty on insurrection charges over the July 15 protest to reopen Freedom Park that turned violent, and a further three have been arrested this month after an appeal from Prime Minister Hun Sen.



Interior Minister SarKheng gestures toward deputy opposition leader KemSokha on Monday at the National Assembly in Phnom Penh, where the two met to discuss recent political issues. (SivChanna/The Cambodia Daily)

Opposition leader Sam Rainsy has been in Europe and the U.S. since the day the 11 sentences were handed down on July 21, and Mr. Sokha has led the opposition party's campaign to have the activists released.

Monday's meeting between Mr. Kheng and Mr. Sokha took place behind closed doors, and the two leaders-wearing broad smiles as they walked out-declined to speak to reporters, sending spokesmen to address the media instead.

Interior Ministry Secretary of State SakSetha, who represented Mr. Kheng, said the two leaders discussed many issues, including the activists, despite a CPP spokesman saying Sunday that such talks would impact judicial independence.

"Regarding the arrests of the people who committed crimes, that is the legal process. In fact, the two leaders discussed the issue but agreed that the discussion would not in any way impact on the legal process," Mr. Setha said.

"We are trying to look for a method to give advice and ideas [to the courts] but those ideas and advice must not affect the legal process or the court's authority," he added.

Asked to specify what such advice could entail, Mr. Setha said that one example could be that the legal processes should be followed properly, or that the CNRP activists get lawyers. In fact, the 11 activists convicted of "insurrection" and the three others arrested this month already have lawyers.

CNRP lawmaker EngChhayEang, who represented Mr. Sokha, told reporters that the opposition was satisfied with the results of the discussion and would seek to free the activists through legal processes.

"For this issue, we discussed this a lot, and at the end the two party leaders agreed to what SakSetha said, and we will use the legal processes to solve this problem," Mr. ChhayEang said without elaborating.

The CNRP has repeatedly accused the country's courts of being corrupt and under the CPP's influence.

Mr. ChhayEang also told reporters that it was clear the seven CNRP lawmakers briefly imprisoned in the days between the July 15 protest and the July 22 deal last year on charges of "leading an insurrection" would remain safe thanks to their parliamentary immunity from prosecution.

"For the seven lawmakers, due to their immunity the court cannot detain or arrest them," he said.

Mr. Hun Sen has repeatedly threatened the lawmakers with trials, but the Phnom Penh Municipal Court has not summoned any for questioning since Mu Sochua, who led the protest last year and remained silent during questioning on May 11.

Separately, Mr. Setha, the Interior Ministry official, said Mr. Kheng and Mr. Sokha had discussed the recently passed and highly controversial NGO law, the legality of which is presently being checked by the Constitutional Council.

Mr. Setha said the government could not intervene in that process but that once the law is passed by the council and signed by King NorodomSihamoni, the CPP may discuss negotiating changes with the CNRP.

"The process is underway, but when it is implemented, if there are impacts on rights and the people's interests, the two parties agreed to address those impacts and to amend [the law] in order to resolve those impacts," he said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការចាប់ខ្លួនពាក់ព័ន្ធរឿងនយោបាយបន្ទុចបង្អាក់រូបភាព ទំនាក់ទំនងល្អកល្អិនរវាងបក្សទាំងពីរ

**ដោយ អេឡិក វិល្លីមមីនស៍ និងម៉ិច ដារ៉ា** | **August 18, 2015**

**ព័ត៌មានវិភាគ**

ដោយប្រយ័ត្នប្រយែងនៅពេលប្រឈមមុខនឹងគ្រោះថ្នាក់ខាងនយោបាយកាន់តែខ្លាំងឡើង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឃ្លាំមើលអស់រយៈពេលបីខែមកហើយក្នុងពេលដែលគណបក្សសង្គ្រោះជាតិធ្វើយុទ្ធនាការប្រទូសប្រឆាំងដោយចោទប្រកាន់រដ្ឋាភិបាលរបស់លោកថា បានកាត់ទឹកដីកម្ពុជាមួយភាគធំឱ្យទៅវៀតណាម។

មិនយូរប៉ុន្មានភាពស្ងាត់ស្ងៀមរបស់លោកបានបើកផ្លូវឱ្យមានការសុខចិត្តមិនធ្លាប់មានដើម្បីកែតម្រូវបង្គោលព្រំដែនដែលបោះមិនបានត្រឹមត្រូវនៅក្នុងទឹកដីរបស់កម្ពុជា និងការដាក់សំណើទៅអង្គការសហប្រជាជាតិព្រមទាំងប្រទេសមួយចំនួនទៀតដើម្បីស្នើសុំផែនទីកម្ពុជាយកមកផ្ទៀងផ្ទាត់ជាមួយផែនទីដែលរដ្ឋាភិបាលកំពុងប្រើប្រាស់។

បន្ទាប់មក ពីរថ្ងៃក្រោយពីលោក រៀល ខេមរិន្ទ្រ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានដឹកនាំប្រជាពលរដ្ឋប្រមាណ២.៥០០នាក់ដើម្បីចុះពិនិត្យមើលការទន្ទ្រានរបស់វៀតណាម ចូលក្នុងទឹកដីខេត្តស្វាយរៀងសកម្មជនគណបក្សប្រឆាំង ១១រូបត្រូវបានផ្តន្ទាទោសភ្លាមៗឱ្យជាប់ពន្ធនាគារតាមការចោទប្រកាន់ពីបទដឹកនាំ និងចូលរួមកុបកម្ម។

លោក សម រង្ស៊ី បានបកស្រាយពីអឺរ៉ុបមកថា សេចក្តីសម្រេចនេះ គឺជាសារប្រាប់ទៅគណបក្សសង្គ្រោះជាតិឱ្យបញ្ឈប់យុទ្ធនាការព្រំដែនរបស់ខ្លួន ប៉ុន្តែប្រាំថ្ងៃក្រោយមកបែរជាចោទប្រកាន់រដ្ឋាភិបាលរបស់លោក ហ៊ុន សែន ថា បានគាំទ្រវៀតណាមដែលបានចូលត្រួតត្រាទីតាំងដីដែលលោក រៀល ខេមរិន្ទ្រ បានចុះទៅពិនិត្យមើល។

ទោះជាយ៉ាងណា ប្រសិនបើទោសរបស់សកម្មជនទាំងនេះមិនបានជះឥទ្ធិពលលើលោក សម រង្ស៊ី ទេនោះ ការចាប់ខ្លួនលោក ហុង សុខហួរ សមាជិកព្រឹទ្ធសភាគណបក្សប្រឆាំងដែលជាមិត្តជិតស្និទ្ធ និងដែលមានសញ្ជាតិបារាំងដូចគ្នា កាលពីថ្ងៃសៅរ៍នោះ បានបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀត ដោយលោក សម រង្ស៊ី បានសន្យាកាលពីម្សិលមិញថា នឹងឈប់វាយប្រហារគណបក្សប្រជាជនកម្ពុជាលើបញ្ហាព្រំដែន។

បន្ទាប់ពីសួរសុខទុក្ខសកម្មជនជាប់ពន្ធនាគាររបស់គណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី បានមានប្រសាសន៍ទៅកាន់ក្រុមអ្នកយកព័ត៌មានថា "យើងឈប់ចាក់ក្រឡេកគ្នារឿងអ្វីៗទាំងអស់ពីព្រោះជួនណាមិនត្រូវមកនិយាយជាសាធារណៈជួនណាវាខូចការណ៍វិញទេ មិនទាន់បានការផងការងារកំពុងតែធ្វើមិនទាន់បានសម្រេច បើយើងនិយាយជាសាធារណៈមកលាតត្រដាងជួនណាមានខុសជួនណាមានត្រូវ វាបែកភក់បែកម៉ាំ វាអត់មានចំណេញទេ។ តែបើយើងធ្វើការជាមួយគ្នា វាមានប្រសិទ្ធភាពជាង"។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយ និងជាស្ថាបនិកវេទិកាអនាគត មានប្រសាសន៍ថា លោក ហ៊ុន សែន បានបញ្ជូនសារយ៉ាងច្បាស់ទៅលោក សម រង្ស៊ី ថា ការយកបញ្ហាព្រំដែនធ្វើជារឿងនយោបាយនឹងធ្វើឱ្យលោកកាន់តែផ្ទុះកំហឹងខ្លាំងឡើង។

លោកបានលើកឡើងថា "ជាមូលដ្ឋាន កាលពីពេលថ្មីៗនេះ គណបក្សប្រជាជនបានព្យាយាមដោះបញ្ហារសើបដ៏ធំមួយដែលបានតាមលងបន្លាចពួកគេ ហើយពួកគេបានធ្វើរឿងនេះតាមរយៈការបង្ហាញថា ពួកគេកំពុងចាប់ខ្លួនជនអន្តោប្រវេសន៍វៀតណាម និងបញ្ជូនពួកគេត្រឡប់ទៅវិញ។ វាបានបង្ហាញយ៉ាងច្បាស់តាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដែលមានទំនាក់ទំនងនឹងគណបក្សប្រជាជនថា ពួកគេកំពុងតាមចាប់ខ្លួនជនជាតិវៀតណាមហើយប្រឆាំងការប្រើវោហារសាស្ត្ររបស់គណបក្សប្រឆាំងដើម្បីបញ្ឈប់បញ្ហានយោបាយដ៏រសើបនេះ។ ហើយការដែលប្រជាពលរដ្ឋរាប់ពាន់នាក់ទៅព្រំដែន គឺជាសេនារីយូករណីអាក្រក់បំផុតសម្រាប់រឿងនេះ។ លោក ហ៊ុន សែន ចង់ធ្វើសេចក្តីថ្លែងការណ៍អំពីរឿងនេះ"។

លោក សម រង្ស៊ី មានប្រសាសន៍ថា ការចាប់ខ្លួនបែបនេះមិនធ្វើឱ្យប៉ះពាល់ដល់ "វប្បធម៌សន្ទនា" ជាមួយលោក ហ៊ុន សែន ដែលបានចាប់ផ្តើមបន្ទាប់ពីមានកិច្ចព្រមព្រៀងនយោបាយកាលពីឆ្នាំមុន និងដែលមានបំណងលើកកម្ពស់បរិយាកាសគ្មានការគំរាមកំហែង និងអំពើហិង្សានៅមុនការ

**តទៅទំព័រទី ១៥**

# Recent Arrests Disrupt Charade of Political Truce

**BY ALEX WILLEMYNS AND MECH DARA | AUGUST 18, 2015**

Cautious in the face of mounting political danger, Prime Minister Hun Sen watched for three months as the opposition CNRP advanced a hostile campaign accusing his government of surrendering swaths of Cambodian territory to Vietnam.

His silence soon gave way to unprecedented offers to rectify border posts improperly placed inside Cambodia's territory, and requests to the U.N. and foreign countries for maps of Cambodia to check against the one being used by the government.

Then, two days after CNRP lawmaker Real Camerin led some 2,500 people to inspect a reported Vietnamese incursion in SvayRieng province, 11 opposition activists were suddenly sentenced to prison on charges of insurrection.



Opposition leader Sam Rainsy leaves Phnom Penh's Prey Sar prison on Monday. (SivChanna/The Cambodia Daily)

From Europe, Mr. Rainsy interpreted the decision as a message to the CNRP to end its border campaign, but five days later accused Mr. Hun Sen's government of standing by as Vietnam annexed the land Mr. Camerin visited.

If the activists' sentences failed to sway Mr. Rainsy, however, the arrest of opposition Senator Hong Sok Hour-a close friend and fellow French citizen-on Saturday proved more persuasive, with Mr. Rainsy pledging Monday to stop attacking the CPP on the border.

"If we know they are sensitive, we won't poke their waists, we will look for a [new] way. When we know they are sensitive, we have to be careful and comfort them somehow to find a result for the nation," Mr. Rainsy said to reporters after visiting the CNRP's jailed activists.

"If a job is proceeding, and we talk about it publicly and openly, sometimes there are things that are right and things that are wrong, and [it is like] mixing mud with fish paste," he said. "If we work together…it is a more effective way."

OuVirak, a political consultant and founder of the Future Forum think tank, said that Mr. Hun Sen had delivered a clear message to Mr. Rainsy that further politicking on the border would only lead to more of his wrath.

"Basically, the CPP has recently been trying to remove the one major sensitive issue that has haunted them, and they have been doing this by showing they are arresting illegal Vietnamese immigrants and sending them back," Mr. Virak said.

"It has been very clear in local media, in the CPP-affiliated press, that they are going after the Vietnamese, and taking on the rhetoric of the opposition in order to stop this sensitive political issue," he said.

"And thousands of people going to the border is the worst case scenario for this," he added. "Hun Sen wanted to make a statement about this."

Mr. Rainsy has said such arrests are not damaging to his "culture of dialogue" with Mr. Hun Sen, which began after last year's political deal and was meant to foster an atmosphere free of threats and violence leading up to the 2018 national election.

Kem Ley, a political analyst who recently helped create the Grassroots Democracy Party as an alternative to the two main parties, said Mr. Rainsy's helplessness in the face of political arrests exposed the futility of his "dialogue" with the prime minister.

"From the beginning until now, the culture of dialogue has been useless. A culture of dialogue should have clear mechanisms to solve issues, but the CNRP only do not want to fight the government anymore," he said.

Mr. Ley said Mr. Hun Sen was trying to ramrod a cautious Mr. Rainsy into submission.

"The main purpose of the government is to end freedom of expression on the border issue, and to legitimize the border postings, and they want the opposition to support what they have done so far in talks with Vietnam," Mr. Ley said.

"This is the CPP's political culture," he said.

Yet Mr. Rainsy said by telephone Monday that the arrests of Mr. Sok Hour and the other activists were symbols of the opposition's recent success in damaging the CPP, and said the culture of dialogue has limited the blowback.

"The situation would be much worse now without the culture of dialogue, because thanks to the culture of dialogue there has been damage control and there are still some lines of communication," Mr. Rainsy said. "With the culture of dialogue, we can still control the situation."

**Continued to Page 13**

## តមកពីទំព័រទី ០៩ ពិធីប្រណាំងទូកនៅឡូវែល

អធមដល់ដំបន់ដោយមានការប្រគល់ប័ណ្ណកោតសសើរពីអភិបាលរដ្ឋម៉ាសាឈូសិតផង នឹងអភិបាលក្រុងឡូវែលផង ។ នៅពេលជាមួយគ្នានោះ ក៏មានការបង្ហាញខ្លួនបេក្ខជនគណកម្មការសាលាក្រុងខ្មែរ៧រូបគឺ វ៉ាស្នា នួន ។ ប៉ាន សូ នឹង រដ្ឋា យ៉ែម ដោយ រីដា មើស៊ើ ដំណាងឱ្យអភិបាលក្រុង រ៉តនី អេលីយ៉ុត។ តាមពិតទៅបេក្ខជនជាខ្មែរមានដល់ទៅ៤រូបឯណោះសម្រាប់សាលាក្រុង គឺ ចិត្ត គីម ម្នាក់ទៀតដែលមិនបានបង្ហាញខ្លួនលើឆាកនឹងបេក្ខជនខ្មែរខាងគណកម្មការសាលារៀន មាន២រូបគឺ ដូមិនិក ហុក ឡាយ នឹង ខាមារា ខៃ។ បោះឆ្នោតឆ្នាំនេះនឹងប្រែមុខមាត់នយោបាយនៅឡូវែលយ៉ាងសម្បើមជាមិនខាន។

ម៉ោង៤រសៀល ទូក២ចុងក្រោយបានមកដល់ទីយ៉ាងប្រកៀកគ្នា គឺទូកប៉ាយ៉ាណាក់ នឹងទូកញូអ៊ិនគ្លិនដែលត្រូវការសេចក្តីសម្រេចពីគណ-កម្មការប្រណាំងទូក...ចុងបញ្ចប់ពានរង្វាន់លេខពីរបានទៅក្រុមប៉ាយ៉ាណាក់នឹងជ័យលាភីឆ្នាំ២០១៥ រង្វាន់លេខមួយបានទៅ ញូអ៊ិនគ្លិន ៕



ខាមម៉ារ៉ា ខៃ

ដូមីនិក ហុក ឡាយ





កញ្ញាធ្លាក់ទឹកនៅឡូវែល








យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យ ដោយមិនបង់ប្រាក់ ដែលរួមមាន៖*
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស)*
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប*
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526(ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

AMERICAN MUFFLER & BRAKE
យានដ្ឋានខ្មែរជួសជុលរថយន្តទូទៅតម្លៃសមរម្យ

Known as A muffler man. Customize pipe, exhaust & welding. come to see us we can make the different.
Shock & Struts, Tune-up, Axle Trans, Timing Belt, Customized Pipe Exhaust Clutch, Water Pump, Starter and much more...
1380 Park Ave.
Cranston, RI 02920
Cell: 203-522-2174
www. amufflerman.com
WE FIX-U $SAVE
Monday-Saturday 8:00 am-7:00 pm Phone: 401-944-3390
Open Sunday 9:00 am-3:00 pm Fax: 401-944-3390
Mony, Chay, Sokheang, Sokheng & Jimmy
WE ARE AT FIVE LOCATIONS
1412 Park Ave. Bridgeport, CT 06604 (203) 333- 0355
335 Whalley Ave. New Haven, CT 06511 (203) 777- 9800
1355 South Main St. Waterbury, CT 06706 (203) 757-7575
219N. Colony Rd. Wallingford, CT 06492 (203) 284-0861

Continued from page 11

## Recent Arrests Disrupt Charade …

"The CPP is kind of desperate. They are panicking. This wave of arrests shows they are panicking and losing ground. It does not show strength. If you were confident in your popularity, you would not do that," the opposition leader said.

"Hun Sen now is not happy-angry and frustrated-by the border issue," he added. "When we create the conditions conducive to changes in his mind, we can find common ground on issues like the border."

CPP spokesman SokEysan said he was grateful that Mr. Rainsy now acknowledged he was provoking the government with the border campaign, but said he doubted the opposition leader's sincerity in saying he would now end it.

"He seems to have woken up, because previously he never talked about poking the government's waist, and now he has said it, therefore he knows it was his error. His words 'poke the waist' have a lot of meaning," Mr. Eysan said.

"We will wait and see whether he can do it [keep his word] or not. I do not believe it."

រកអ្នកធ្វើការ -ជាងធ្វើក្រចកស្រី ឬប្រុស
ប្រាក់ខែជូនទៅតាមបទពិសោធន៍ពី $៥០០-$១.០០០ ក្នុង១អាទិត្យ
កន្លែងធ្វើការរវល់ច្រើន
Trenton, NJ ចម្ងាយ៤៥នាទី ពីហ្វីឡាដែលហ្វៀ
សម្រាប់អ្នកនៅឆ្ងាយមានកន្លែងឱ្យសំណាក់
ទូរស័ព្ទ : **609-227 1939**

Help wanted – Nail Technician M or F
Salary base on experience $500-$1,000/week
Busy location, Trenton, NJ 45mn.from Philly
For long distance, Provided accommodation
Call **609-227 1939**

**Your classify ad is here for only $50 per month**
ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ
ចំណាយចំណាយត្រឹមតែ
**$50** ក្នុង១ខែ
*CALL:*
***978.677.7163***
*EMAIL: SOBENPIN@KHMERPOST.US*

**សន្សំលុយថ្លៃប្រើភ្លើង និងហ្គាស**
Pay less for
Electric and Gaz bill
Only**8.50**cent/kwh
Just switch supplier to : Ambit
"no cost to switch"
"No hidden fees"
Call Roger
**(978) 942 1641**
**or Alex (978)569 6034**


CONWAY
INSURANCE AGENCY
រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :
ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខិខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ខូម៉ែរ សិប្បកម្មច្នៃរូបសំណាកក្រានីត
COLMER MONUMENT WORKS
Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821

- Granite Memorials ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers ផ្នូរផ្តេកមានឆ្លាក់សរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works
ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

# ព័ត៌មានខ្លីៗ ១ : លោក ចិត្ត គិម បើកយុទ្ធនាការឃោសនា

## Cheth Khim for Lowell City Council Campaign Kick-off

**ដោយ ខ្មែរផុស ស.រ.អា**

បេក្ខជនគណក្រុមប្រឹក្សាសាលាក្រុងឡូវែល ឆ្នាំ២០១៦ ថ្មីម្នាក់ទៀត គម្រប់ជាបេក្ខជនខ្មែរ-អាមេរិកាំងទី៤ ឈ្មោះ ចិត្ត គិម បានបើកពិធីជប់លៀងបង្ហាញពីបេក្ខភាពរបស់ខ្លួនជាសាធារណ នៅចំពោះមុខភ្ញៀវប្រមាណ១៥០នាក់ ដែលបានមកចូលរួមអបអរ។ នេះជាឯកគទកម្មក្នុងចំនួនបេក្ខជន នឹងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀត ដែលសហគមន៍ខ្មែរ-អាមេរិកាំងនៅឡូវែល មានបេក្ខជនគណក្រុមប្រឹក្សាសាលាក្រុងឡូវែល ចំនួន៤នាក់ជាលើកទី១ ចូលរួមព្រឹត្តការណ៍នយោបាយនៅសហរដ្ឋអាមេរិកនេះ។

នៅក្នុងសុន្ទរកាថាបង្ហាញខ្លួន លោក ចិត្ត គីម បានឱ្យដឹងថា លោកមានក៏រឹតសិក្សាចប់មហាវិទ្យាល័យ ។ ហេតុដែលលោកមកឈរឈ្មោះជាបេក្ខជនសាលាក្រុងឡូវែលនេះ បុព្វហេតុមានតែ១ គឺចង់ជួយសហគមន៍ខ្មែរ ហើយបើនរណាចង់បំពេញសំណុំរឿងក្រដាស់ស្នាមផ្សេងៗ ចង់ពិគ្រោះបញ្ហាសង្គម ឬតុលាការ...។ សូមឱ្យមករកលោកចុះ ហើយទៅអនាគតទៅក៏ដូចគ្នាដែរ ។ លោកបន្តថា លោកគ្មានប្រកាន់គណបក្សណាទេ តែលោកចង់ឃើញថវិការក្រុងឡូវែល ចែកចាយមកដល់សង្កាត់លេខ១៨ ដែលសម្បូរខ្មែររស់នៅឱ្យបានច្រើន ដូច្នេះសូមអញ្ជើញបោះឆ្នោតឱ្យលោក។




ភ្ញៀវជាច្រើនជាមនុស្សប្លែកមុខពីភ្ញៀវនៃបេក្ខជន វ៉ាស្នា នួន នឹង បេក្ខជន រដ្ឋា យ៉ែម ដែលជាមនុស្សរស់នៅឡូវែលយូរឆ្នាំមិនបានឃើញមុខនៅទីនោះទេ។ បេក្ខជន ប៉ាន សូ បានមកចូលរួមជាលោកគ្រូចាស់ស្រុកឡូវែលបាននិយាយថា លោកនឹងធ្វើពិធីជប់លៀងរបស់លោកនៅពេលក្រោយបោះឆ្នោតជុំទីមួយ បើលោកជាប់ឆ្នោត។ ភ្ញៀវខ្លះនិយាយថា ខ្លួនចង់ឃើញមនុស្សជំនាន់ថ្មីចូលមកឈរឈ្មោះរបៀប ចិត្ត គីម នេះ ពីព្រោះវានឹងប្តូររបៀបគិតនៃសង្គមខ្មែរនៅឡូវែលនេះ ។ ពិធីប្រកបដោយភ្លេងចំរៀងដ៏ពីរោះអ្នករាំកំសាន្ត ក៏ជាភ្ញៀវឆើតតែគេមិនបានឃើញចែកឯកសារទុកឱ្យភ្ញៀវយកទៅអាននៅផ្ទះ ដូចដែលបេក្ខជនទាំងឡាយធ្លាប់ធ្វើនោះទេ៕

# អត្ថប្រយោជន៍គ្រាប់ជីចំពោះសុខភាព

គ្រាប់ជីជាឱសថធម្មជាតិដ៏ល្អមួយប្រភេទដែលប្រជាជនខ្មែរពេញនិយមទទួលទានដោយសារវាអាចកាត់បន្ថយការស្រេកទឹក និងអាការក្តៅក្នុង។ ប៉ុន្តែក្រៅពីនេះ គ្រាប់ជីនៅមានអត្ថប្រយោជន៍ ចំពោះសុខភាព និងសម្រស់ជាច្រើនទៀត ហួសពីការស្មាន។



**១.** គ្រាប់ជីសម្បូរទៅដោយសារធាតុអូមេហ្គា ៣ ដែលល្អសម្រាប់សុខភាពខួរក្បាល និងបេះដូង ហើយវាក៏មានផ្ទុកជាតិអូមេហ្គា ៣ ច្រើនជាងត្រីសូម៉ុងដល់ទៅ៨ដង។

**២.** សម្បូរជាតិសរសៃច្រើន ហើយអត្ថប្រយោជន៍របស់វាមានដូចជាល្អចំពោះប្រព័ន្ធបញ្ចេញចោលជួយព្យាបាលជំងឺក្តៅក្នុងការពារប្រព័ន្ធរំលាយអាហារ និងល្អសម្រាប់ស្ត្រីមានផ្ទៃពោះ។

**៣.** គ្រាប់ជីគ្មានសារធាតុគីមីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព។

**៤.** វាមានជាតិប្រូតេអ៊ីន២០% ខ្ពស់ជាងផ្លែឈើមួយចំនួន។

**៥.** ប្រូតេអ៊ីនដែលមានក្នុងគ្រាប់ជីមានផ្ទុកទៅដោយអាស៊ីដអាមីណូទាំង៨ប្រភេទ។

**៦.** គ្រាប់ជីមានសមត្ថភាពខ្ពស់ក្នុងការប្រឆាំងនឹងសារធាតុអុកស៊ីតកម្ម។

**៧.** សម្បូរទៅដោយសារជាតិកាល់ស្យូមច្រើនជាងទឹកដោះគោ៥ដង។

**៨.** វាមានផ្ទុកវីតាមីន C ច្រើនជាងក្រូច៧ដង។

**៩.** មិនត្រឹមតែប៉ុណ្ណោះវាមានផ្ទុកជាតិដែកច្រើនជាងស្ពៃខ្មៅ៣ដង។

**១០.** វាមានសារធាតុប៉ូតាស្យូមច្រើនជាងផ្លែចេក២ដង។

**១១.** ផ្តល់ឱ្យមានតុល្យភាពជាតិស្ករក្នុងឈាមត្រឹមត្រូវល្អ។

**១២.** មិនត្រឹមតែល្អចំពោះសុខភាពប៉ុណ្ណោះទេ វាក៏ល្អចំពោះសម្រស់ដែលធ្វើឱ្យស្បែក ក្រចក និងសក់មានសុខភាពល្អ ។

**ចំណាំ:** ចំពោះការទទួលទានគ្រាប់ជីមួយថ្ងៃបានតែ១៥ក្រាមប៉ុណ្ណោះ ហើយត្រូវផឹកទឹកឱ្យបានច្រើន ដោយសារគ្រាប់ជីសម្បូរជាតិសរសៃច្រើន៕



# ការវិភាគ

### របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

<u>គណបក្សប្រជាជនបានប្រើយុទ្ធសាស្ត្រចរចាផងវាយផង</u>

ស្ថានការណ៍ឡើងកម្តៅខ្លាំង នៅពេលដែលលោករៀលខេមរិន្ទ្រនាំគ្នាទៅពិនិត្យព្រំប្រទល់ខ្មែរវៀតណាម ដែលគេសង្ស័យថា ផែនទីដែលវាស់ព្រំដែនបាន៨៣ភាគរយនោះ ពុំមែនជាផែនទីដែលរដ្ឋាភិបាលប្រគល់ឲ្យលោកសុខទូចឡើយ។ បើតាមសំដីរបស់លោកវ៉ាគិមហុងថា ផែនទីដែលវាស់នោះបានមកពីវៀតណាម។ គេសង្ស័យទៀតថា បើរដ្ឋាភិបាលអះអាងថា វាស់បានត្រឹមត្រូវហើយដោយវាស់តាមផែនទីដែលសម្តេចសីហនុយកទៅដំកល់នៅអង្គការសហប្រជាជាតិស្របតាមរដ្ឋធម្មនុញ្ញ។ចុះបើត្រឹមត្រូវហើយហេតុអ្វីបានជាពេលនេះ ផ្ញើលិខិតទៅសុំផែនទីពីអង្គការសហប្រជាជាតិនិងមហាអំណាចទាំង៣ធ្វើអ្វីទៀត? ដូច្នេះតើគេអាចនិយាយបានថា គ្មានវាស់តាមផែនទីត្រឹមត្រូវឡើយ គឺវាស់តាមផែនទីដែលយួនប្រគល់ឲ្យវាស់ តាមសន្ធិសញ្ញាខុសច្បាប់ បើគេយល់ដូច្នេះត្រឹមត្រូវឬទេ? គេមិនត្រូវកែមាត្រា២នៃរដ្ឋធម្មនុញ្ញឡើយ ថ្ងៃក្រោយបើខ្វះខាតគេអាចបន្ថែមទៅវិញ។ គណបក្សប្រជាជនបំណងរំលាយគណបក្សសង្គ្រោះជាតិដោយវិធី៣យ៉ាង។

១- ការចរចាដោយបង្កើតវប្បធម៌សន្ទនា បង្កើតប្រធានសម្លេងភាគច្រើននិងសម្លេងភាគតិច ដោយទីមួយខ្ទប់មាត់កុំឲ្យគណបក្សសង្គ្រោះជាតិរិះគន់គណបក្សប្រជាជន។ ច្បាប់គណៈកម្មាធិការបោះឆ្នោតនិងច្បាប់គ្រប់គ្រងអង្គការនិងសមាគមមានភាពល្អខ្លះកន្លែងខ្លះរឹតបន្តឹង។ គណបក្សសង្គ្រោះជាតិសុំឲ្យដោះលែងសកម្មជនរបស់ខ្លួន១៤នាក់ដែលចាប់ដោយផ្លូវនយោបាយ គេថាស្ថិតនៅលើច្បាប់តុលាការ។ល។

២-ចរចាផងវាយផងដោយចាប់សកម្មជនគណបក្សសង្គ្រោះជាតិ១៤នាក់ដែលពូកែនិយាយខ្ទប់មាត់ ប្រឌិតចោទរៀលខេមរិន្ទ្រថាពុករលួយព្រោះល្បីឈ្មោះនាំគេទៅមើលព្រំប្រទល់ដែន ចាប់ចោទលោកហុងសុខហួរដើម្បីវាយបំបាក់អ្នកជើងខ្លាំង។ល។

៣-គាំទ្រគណបក្សតូចៗដើម្បីបំបែកសម្លេងពីគណបក្សសង្គ្រោះជាតិ។ល។

វត្តខ្មែរកាណាដា,ថ្ងៃ១៥សីហា២០១៥;www.hoksavann.org;savannhok@yahoo.com

## តមកទំព័រទី ១១ ការចាប់ខ្លួនពាក់ព័ន្ធរឿងនយោបាយ...

បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ឡើយ។

លោក កែម ឡី អ្នកវិភាគនយោបាយឯករាជ្យ ដែលក្នុងពេលថ្មីៗនេះបានជួយបង្កើតគណបក្សប្រជាធិបតេយ្យមូលដ្ឋាន ដើម្បីជាជម្រើសមួយផ្សេងក្រៅពីគណបក្សធំៗទាំងពីរបានលើកឡើងថា ការដែលលោក សម រង្ស៊ី មិនអាចជួយអ្វីបានក្នុងពេលប្រឈមនឹងការចាប់ខ្លួនពាក់ព័ន្ធរឿងនយោបាយ បង្ហាញឱ្យឃើញថា "វប្បធម៌សន្ទនា" របស់លោកជាមួយលោកនាយករដ្ឋមន្ត្រីគ្មានប្រយោជន៍។

លោកបានមានប្រសាសន៍ថា "ចាប់តាំងពីដើមទីរហូតមកទល់ពេលនេះ វប្បធម៌សន្ទនាគ្មានប្រយោជន៍អ្វីទេ។ វប្បធម៌សន្ទនាគួរតែមានយន្តការច្បាស់លាស់ដើម្បីដោះស្រាយបញ្ហា ប៉ុន្តែគណបក្សសង្គ្រោះជាតិមិនចង់តស៊ូប្រឆាំងនឹងរដ្ឋាភិបាលតទៅមុខទៀតទេ"។

លោកបានលើកឡើងបន្តថា លោក ហ៊ុន សែន បានព្យាយាមបង្ខំឱ្យលោក សម រង្ស៊ី ទទួលយកនូវអ្វីដែលលោកកំពុងតែឃ្លាំមើលយ៉ាងយកចិត្តទុកដាក់។

លោកមានប្រសាសន៍ថា "គោលបំណងសំខាន់របស់រដ្ឋាភិបាល គឺចង់បញ្ចប់សេរីភាពបញ្ចេញមតិជុំវិញបញ្ហាព្រំដែន ហើយចង់ធ្វើឱ្យមានការកំណត់បង្គោលព្រំដែនស្របច្បាប់ និងចង់ឱ្យគណបក្សប្រឆាំងគាំទ្រនូវអ្វីដែលខ្លួនបានធ្វើមកទល់នឹងពេលនេះនៅក្នុងការចរចាជាមួយវៀតណាម។ នេះគឺជាវប្បធម៌មិនយោបាយរបស់គណបក្សប្រជាជន"។

ប៉ុន្តែលោក សម រង្ស៊ី បានលើកឡើងតាមទូរស័ព្ទកាលពីម្សិលមិញថា ការចាប់ខ្លួនលោក ហុង សុខហួរ និងសកម្មជនផ្សេងៗទៀតគឺជានិមិត្តរូបនៃភាពជោគជ័យក្នុងពេលថ្មីៗនេះរបស់គណបក្សប្រឆាំងក្នុងការធ្វើឱ្យគណបក្សប្រជាជនកម្ពុជារងផលប៉ះពាល់ ហើយថា វប្បធម៌សន្ទនាបានជួយរារាំងកុំឱ្យស្ថានភាពនយោបាយធ្លាក់ក្នុងស្ថានភាពដ៏អាក្រក់។

លោកបានមានប្រសាសន៍ថា "ស្ថានភាពអាចនឹងអាក្រក់ខ្លាំងនៅពេលនេះ បើគ្មានវប្បធម៌សន្ទនា ព្រោះដោយសារវប្បធម៌សន្ទនា ទើបមានការគ្រប់គ្រងភាពខូចខាតនិងនៅតែមានការសន្ទនាគ្នាមួយចំនួន។ ដោយសារវប្បធម៌សន្ទនានេះ យើងអាចគ្រប់គ្រងស្ថានភាពបាន"។

មេដឹកនាំគណបក្សប្រឆាំងរូបនេះបានមានប្រសាសន៍បន្ថែមថា "គណបក្សប្រជាជនកម្ពុជាកំពុងតែអស់សង្ឃឹម។ ពួកគេកំពុងតែភ័យខ្លាច។ ការចាប់ខ្លួនជាបន្តបន្ទាប់នេះបង្ហាញឱ្យឃើញថា ពួកគេកំពុងតែភ័យខ្លាចនិងបាត់បង់ជំហរ។ វាមិនបង្ហាញពីភាពខ្លាំងទេ។ ប្រសិនបើពួកគេជឿជាក់លើប្រជាប្រិយភាពរបស់ខ្លួន ពួកគេមិនធ្វើអ៊ីចឹងទេ។ ឥឡូវនេះ លោក ហ៊ុន សែន មិនសប្បាយចិត្តទេ ឱ្យខឹង និងមួម៉ៅ ដោយសារបញ្ហាព្រំដែន។ នៅពេលយើងបង្កើតលក្ខខណ្ឌដែលងាយស្រួលធ្វើឱ្យគាត់ផ្លាស់ប្តូរចិត្តយើងអាចរកឃើញមតិរួមលើបញ្ហាដូចជាបញ្ហាព្រំដែនជាដើម"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងថា លោកសូមអរគុណដែលឥឡូវនេះលោក សម រង្ស៊ី បានទទួលស្គាល់ថា ខ្លួនកំពុងតែរករឿងរដ្ឋាភិបាលដោយបើកយុទ្ធនាការពាក់ព័ន្ធបញ្ហាព្រំដែន ប៉ុន្តែថាលោកមានការសង្ស័យចំពោះភាពស្មោះត្រង់របស់មេដឹកនាំគណបក្សប្រឆាំងរូបនេះដែលថា ខ្លួននឹងបញ្ចប់បញ្ហានេះ។

លោកមានប្រសាសន៍ថា "គាត់ហាក់ដូចជាទើបភ្ញាក់ពីដេក ព្រោះកាលពីមុនគាត់មិនដែលនិយាយអំពីការចាក់ក្រឡេករដ្ឋាភិបាលទេ ហើយឥឡូវនេះគាត់បែរជាមានប្រសាសន៍អ៊ីចឹងដូច្នេះ ហើយគាត់ដឹងថា វាគឺជាកំហុសរបស់គាត់។ ពាក្យ "ចាក់ក្រឡេក" របស់គាត់មានន័យច្រើន។ យើងនឹងរង់ចាំមើលថាតើគាត់អាចធ្វើដូច្នេះឱ្យរក្សាពាក្យសន្យា បានឬអត់។ ខ្ញុំមិនជឿទេ"៕

**សុខុម និង ស៊ុយឈាង**



# ព្រឹត្តិការណ៍ដែលត្រូវពិចារណា



លឹម គិមយ៉ា

លិខិតចេញពីស្ថាប័នប្រឆាំងអំពើពុករលួយនៃអង្គភាពប្រឆាំងអំពើពុករលួយហៅកាត់ថា អេ.ស៊ី.យូ (ACU) នៅថ្ងៃទី៣១ ខែកក្កដា ដែលគេទើបផ្សព្វផ្សាយនៅថ្ងៃទី១១ សីហា ដែលបានផ្ញើទៅអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមណ្ឌលស្វាយរៀង លោក រៀល ខេមរិន្ទ្រ ដោយជំរុញឱ្យបំភ្លឺចំពោះពាក្យបណ្តឹងចំនួន៣ដែលចោទថា លោកបានកេងប្រវ័ញ្ចយកប្រាក់សរុប៥ម៉ឺន៥ពាន់ដុល្លារដែលទទួលយកទៅរៀបចំដំណើរទៅមើលបង្គោលព្រំដែនកន្លងមក។

អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយលោក យាង សេង មានប្រសាសន៍ថា អង្គភាពនឹងបន្តស្នើឱ្យលោក រៀល ខេមរិន្ទ្រ ចាំបាច់ត្រូវបំភ្លឺចំពោះបញ្ហានេះហើយបង្ហាញឯកសារពាក់ព័ន្ធដើម្បីការពារចំពោះការប្តឹងចោទមុននឹងអង្គភាពប្រឆាំងអំពើពុករលួយបន្តនីតិវិធីរបស់ខ្លួន : "ធម្មតាគាត់ចាំបាច់គាត់ត្រូវតែបំភ្លឺហើយ មិនអ៊ីចឹងទេ មានន័យថា គាត់មានកំហុសតាមអ្វីដែលគេចោទប្រកាន់គាត់។ យើងឱ្យគាត់បំភ្លឺដើម្បីគាត់បកស្រាយថាតើគាត់មានស្អីដើម្បីនិយាយថាគាត់មានភស្តុតាងបញ្ជាក់ផ្ទុយ"។

បើតាមនិយមន័យនៅមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី ១៧ មេសា ២០១០ គឺបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងជំពូកទី៦ នៃច្បាប់នេះ។

បើមើលជំពូកទី ៦ នៃច្បាប់នេះ គឺមាត្រា ៣២ បានស្រង់ក្រមព្រហ្មទណ្ឌជាច្រើនមាត្រា ដូចជា: មាត្រា ២៧៨ បទស៊ីសំណូកនៃនយោជិត, មាត្រា២៧៩ បទសូកប៉ាន់នៃនយោជិត, មាត្រា ២៨០ បទស៊ីសំណូករបស់អភិបាលជាអាទិ៍, ២៨៣ កាលទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ។ល។

ជាញឹកញាប់មានបណ្តឹងពីករណីយពុករលួយជាច្រើន ឃើញតែផ្តន្ទាទោសដល់អ្នកបណ្តឹងដោយប្រើមាត្រា៤១ បទប្តឹងបរិហារដោយភូតកុហក មិនដែលសូវឃើញផ្តន្ទាទោសអ្នកចុងចោទទេ គង់តែមានឯកសារគ្រប់គ្រាន់យ៉ាងណាក៏ដោយ ដូចរឿង Global Fund ។ មូលនិធិសកល (Global Fund) បានចេញរបាយការណ៍ស៊ើបអង្កេតមួយកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយបង្ហាញភស្តុតាងជាច្រើនទាក់ទងនឹងបណ្តាញប្រព្រឹត្តអំពើពុករលួយក្នុងក្រសួងសុខាភិបាល។

របាយការណ៍ស៊ើបអង្កេតកម្រាស់ ៨៣ទំព័របូកនិង ឯកសារឧបសម្ព័ន្ធចំនួន១៣៤ទំព័រ របស់មូលនិធិសកលបានរកឃើញថា អតីតប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជម្ងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រលោក ឌួង សុជាតិ និងសហការីម្នាក់បានទទួលប្រាក់សគុណចំនួនជិត៥សែនដុល្លារពីក្រុមហ៊ុនផ្គត់ផ្គង់មុងចំនួនពីរនៅបរទេស ដែលមានឈ្មោះលោកស្រី ឈូនូ គិមចិន្ដា (CHHOUNOU KIMCHENDA) ជាបងប្អូនរបស់លោកបណ្ឌិត ជីហូនូ គិមចិន្ដា (CHI-HOUNOU KIMCHENDA) ជាអ្នកឈរឈ្មោះទទួលលុយ។ ក្រុមហ៊ុនទាំងពីរផ្តល់ប្រាក់សគុណជូនមន្ត្រីទាំងនេះជាថ្នូរនឹងកិច្ចសន្យាជាមួយក្រសួងសុខាភិបាល។ តែអង្គភាពប្រឆាំងអំពើពុករលួយបានយល់ថា មិនមែនជាអំពើពុករលួយទេ តែលោក ឱម យ៉ិនទៀង ជាប្រធានអង្គភាពនេះប្រកាសឱ្យអ្នកពាក់ពន្ធ័សងលុយវិញ គឺដើម្បីបានទទួលអំណោយថែមទៀត ។

ក្នុងករណីយរបស់លោក រៀល ខេមរិន្ទ្រ គឺលោកបានធ្វើការអំពាវនាវដោយផ្ទាល់ខ្លួនរបស់លោកក្នុងការសុំជំនួយពីសប្បុរសជនដើម្បីសកម្មភាពរបស់លោកដែលប្រមែលប្រមូលប្រជាពលរដ្ឋទៅទល់ដែនមើលការរំលោភរបស់យួនលើបូរណភាពទឹកដីខ្មែរ ។ ការរំលោភនេះមានជាច្រើនកន្លែង ។ ហេតុដូច្នេះការចំណាយរបស់លោកមិនទាក់ទងនឹងអាជ្ញាធរអ្វីទេ ហើយការស្នើសុំនេះគឺគ្មានការរៀបចំជាគណកម្មការអ្វីដែលត្រួតពិនិត្យនោះដែរ ហេតុភាពពុករលួយក៏មិនអាចយកមកនិយាយក្នុងករណីយនេះដែរ ។

ប៉ុន្តែយើងយករឿងនេះជាមេរៀនទៅអនាគតដូចជាសកម្មភាពរបស់គណបក្សសង្គ្រោះជាតិប្រមូលជំនួយពីប្រជាពលរដ្ឋ ដើម្បីធ្វើទូរទស្ស ។ រឿងនេះច្បាស់ជាអង្គភាពប្រឆាំងអំពើពុករលួយនឹងសួរគណបក្សសង្គ្រោះជាតិ ហើយនឹងអាចឃាំងខ្ទប់ថវិការនៅធនាគារមិនឱ្យប្រើប្រាស់ទៅបើកទូរទស្សទៀតផង ។

មានរឿងផ្សេងៗទៀតដែលត្រូវតែពិចាណាឱ្យបានច្បាស់លាស់ ដូចជាពួកខ្លះចង់ទៅចូលរួមធ្វើរាជរដ្ឋាភិបាលជាមួយគណបក្សប្រជាជនកម្ពុជាដោយមិនគិតពីផលវិបាក ដោយសារតែមានគំនិតចង់តែបានមិនគិតពីគ្រោះថ្នាក់នោះទេ ។ បើប្រសិនណាជាចូលរួមមែនដោយប្រការណាមួយដោយយើងដឹងថាសមាជិករាជរដ្ឋាភិបាល

**តទៅទំព័រទី១៧**

AccuCare
Home Care Agency
Group Adults Foster Care Program

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើងតាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។*

*ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :*
- *រស់នៅផ្ទះរដ្ឋ*
*អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហែលស្តង់ដា*

*ផលប្រយោជន៍ទទួលបាន :*
- *ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក ២៤ម៉ោង*

***To be eligibled for GAFC you must:***
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ខ្យងស្ងោរជ្រលក់ទឹកត្រី



**ដោយៈ មង្គលការ**

អីយ៉ា! ម្ហូបមួយមុខនេះគ្រាន់តែលឺឈ្មោះភ្លាមដូចជាចង់ស្រក់ទឹកមាត់ភ្លេតតែម្តងហើយ ប៉ុន្តែតើប្រិយមិត្តដឹងទេ ត្រូវធ្វើយ៉ាងម៉េចទើបខ្យងមានរសជាតិឆ្ងាញ់ ហើយមិនធំក្លិនឆ្អាប? គ្មានអ្វីពិបាកទេ អនុវត្តតាមការណែនាំខាងក្រោមទៅជាការស្រេច ។

**គ្រឿងផ្សំ**

- ខ្យងស្ងោរ ៥០០ក្រាម ឆ្កឹះយកសាច់
- គល់ស្លឹកគ្រៃ ២គល់ កាត់កង់ដំឱ្យបែក
- ស្លឹកក្រូចសើច ៥សន្លឹក
- បន្លែអន្លក់ញាំផ្ទាប់ ជីអង្កាម, ជីសាំងឃុំ, សាឡាដ៍, ចេកខ្ចី មួយមុខបន្តិច១

**វិធីធ្វើ**

**១.** ដំបូងដាក់ឆ្នាំងដាំទឹកឱ្យពុះដាក់គល់ស្លឹកគ្រៃ និងស្លឹកក្រូចសើចញីដាក់ចូល ។

**២.** ទុកមួយសន្ទុះដាក់ខ្យងចូលស្ងោរម្តងទៀតមួយពុះប្រហែលជា ២-៣នាទី ។

**៣.** ២-៣នាទីក្រោយមកអាចស្រង់យកមកញាំផ្ទាប់ជាមួយបន្លែជ្រលក់ទឹកត្រីបានហើយ ។

**គ្រឿងផ្សំទឹកត្រីៈ**

ទឹកឆ្អិន ១២០មីលីលីត្រ, ស្ករស ៥០ក្រាម, ទឹកក្រូចឆ្មា ២-៣ស្លាបព្រាបាយ, អំបិល បន្តិច, ទឹកត្រី ២-៣ស្លាបព្រាបាយ, ខ្ទឹមស ៣កំពឹស, ម្ទេស តាមចូលចិត្ត ចិញ្ច្រាំ ដាក់ចូលក្នុងចានលាយចូលគ្នាឱ្យសព្វ ៕

## តមកទំព័រទី ១៦ ព្រឹត្តិការណ៍ដែលត្រូវពិចារណា

បានប្រាក់ខែចាយមិនគ្រប់ទេ តិចជាងនៅសភាទៅទៀត ។ ហេតុនេះត្រូវតែទៅរកក្រៅដើម្បីបង្គ្រប់ចំណាយជារាងរាល់ខែ ។ ការដែលទៅរកក្រៅនេះហើយ ដែលហៅថាអំពើពុករលួយជាអាវុធមួយ ដែលពួកហ៊ុនសែនចាំយកមកវាយប្រហារ ។

បើហ៊ុនសែនយល់ថា អ្នកដែលអាចប្រើការបាន ដើម្បីរំខានដល់ពួកជំទាស់នឹងវា វាមិនធ្វើអ្វីទេ ដោយទុកឱ្យបន្តសកម្មភាពតទៅទៀត។ ហើយបើវាយល់ថាអ្នកនេះ អ្នកនោះស្លូត និងគាំទ្រវាហើយ វាយល់ថា បើទុកក៏មិនបានការ វាឱ្យឈប់ធ្វើនយោបាយ វាមិននឹងធ្វើអ្វីទេ ។ បើអ្នកណាដែលវាស្អប់ពេលនឹងហើយ វានឹងចាប់ដាក់គុក និងរឹបអូសយកទ្រព្យសម្បត្តិដោយយកពីបទអំពើពុករលួយមកប្រើ ។

នេះជាមេរៀន ដែលត្រូវតែពិចារណាឱ្យបានដិតដល់ ចំពោះពួកដែលចង់យ៉ាងរញ៉ីរញ៉ៃរចង់រត់ទៅបំរើ ហ៊ុន សែន គង់តែធ្វើជាឆ្កែគេក៏សុខចិត្តដែរ ។

**លិម គិមយ៉ា**

**តំណាងរាស្ត្រមណ្ឌលកំពង់ធំ**

**សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា**

Allstate.
You're in good hands.
Veasna Chhay
Licensed Sales Producer
Home/Auto/Life MA & RI
Allstate Insurance Company
1535 Smith Street
North Providence, RI 02911
Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com



Personalized service.
Trusted advice.

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com







# ទំនប់រំលិច និងប្រវត្តិ កសាងជួរចត់ប្រែក្លាយជាតំបន់ ទេសចរណ៍ថ្មីនៅកំពត

●●●បច្ចុប្បន្ននេះ ទំនប់ម្លិច បានប្រែក្លាយពីទីលានទុក្ខសោកមកជាតំបន់រមណីយដ្ឋានទេសចរណ៍ដ៏ពេញនិយមមួយសម្រាប់ប្រជាពលរដ្ឋជាភ្ញៀវជាតិ និងអន្តរជាតិចូលទៅទស្សនាបន្តបន្ទាប់ ជាពិសេសនៅថ្ងៃសម្រាកចុងសប្តាហ៍ និងថ្ងៃបុណ្យជាតិធំៗ ព្រោះអំណោយផលទីតាំងនៅជាប់ជួរភ្នំប្រកបដោយទេសភាពស្រស់បំព្រង និងមានទឹកថ្លាឈ្វេងគួរឱ្យចង់ងូតលេងកម្សាន្តយ៉ាងត្រជាក់ចិត្ត។

ម្លិច ឬរំលេច ជាឈ្មោះទំនប់ទឹកមួយដែលមានទីតាំងនៅចន្លោះរវាងខេត្តតាកែវ និងខេត្តកំពត នៅម្តុំចំណុចភ្នំនារាយណ៍ ឬភ្នំមេអំបៅ ដែលជាអតីតសកលវិទ្យាល័យមួយមានចម្ងាយប្រមាណជា៩០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៣ និងចុះទៅពីផ្លូវជាតិប្រមាណជា២ពាន់ម៉ែត្រឆ្ពោះទៅតំបន់ជួរភ្នំ។

មានប្រជាពលរដ្ឋខ្មែរ និងមន្ត្រីរាជការជាច្រើននាក់ដែលបានដឹងអំពីប្រវត្តិទំនប់ម្លិច បានលើកឡើងប្រហាក់ប្រហែលគ្នាថា ការកសាងទំនប់ម្លិច ស្ថិតនៅឃុំជ្រេស ស្រុកជុំគីរី ខេត្តកំពត បានបណ្តាលឱ្យមានមនុស្សស្លាប់រាប់ពាន់ម៉ឺននាក់ ដោយសារការបង្ខំឱ្យធ្វើការហួសកម្លាំងពីមេដឹកនាំខ្មែរក្រហមជំនាន់នោះ។ ទំនប់ម្លិចកសាងឡើងនៅអំឡុងចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ក្នុងសម័យខ្មែរក្រហម។ ការសាងសង់ទំនប់ម្លិច គឺមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវនាតំបន់នោះ បានកេណ្ឌប្រជាជនពីគ្រប់មជ្ឈដ្ឋានទូទាំងខេត្តកំពត ជាពិសេសប្រជាជនជម្លៀសចូលថ្មីឱ្យចុះមកលើកទំនប់នេះទាំងយប់ទាំងថ្ងៃក្នុងគោលបំណងស្តុកទឹកទុក សម្រាប់ប្រើប្រាស់ និងទុកធ្វើស្រែចម្ការច្បារដំណាំជាដើម។

ប៉ុន្តែទោះជាយ៉ាងណាអតីតកាលដ៏ខ្មៅងងឹតក៏បានកន្លងផុត ដោយបន្សល់ទុកនូវទំនប់ម្លិចមកទល់នឹងបច្ចុប្បន្នជាមួយការកែប្រែមុខមាត់ថ្មីក្លាយទៅជាតំបន់ទេសចរណ៍កំពុងពេញនិយមក្នុងចំណោមរមណីយដ្ឋានទេសចរណ៍នានានៅខេត្តកំពត សម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ជាពិសេសប្រជាពលរដ្ឋនៅទូទាំងខេត្តកំពតតែងទៅកម្សាន្តនៅទំនប់ទឹកនេះមិនដែលដាច់រៀងរាល់ថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យជាតិខ្មែរគ្រប់រដូវកាល។

ទំនប់ម្លិច ត្រូវបានអ្នកស្រុករស់នៅជិតខាងអះអាងថា មានទំហំខ្ពងទំនប់ប្រមាណជា១០០ម៉ែត្រ និងមានបណ្តោយជិត១ពាន់ម៉ែត្រសាងសង់ពីចង្កេះភ្នំម្ខាងទៅចង្កេះភ្នំម្ខាងទៀត។ ទំនប់ម្លិចនេះ ក្រៅពីមាននូវអំណោយផលទៅលើវិស័យទេសចរណ៍ទំនប់នេះក៏បានបម្រើដល់ផលប្រយោជន៍រួមរបស់ប្រជាកសិករប្រកបរបរកសិកម្មនៅតំបន់ជិតខាង គឺអាចឱ្យកសិករដាំដំណាំរួមផ្សំ ឬធ្វើស្រែប្រាំងបានជារៀងរាល់ឆ្នាំផងដែរ៕







# ចិត្តគំនិតជនទុច្ចរិត និងចិត្ត គំនិតជនសុចរិត

១-ចិត្តគំនិតនៃជនទុច្ចរិត     រមែងប្រព្រឹត្តដោយមិនខ្លាច
ពីព្រោះជននេះអាងអំណាច     ព្រហើនកោងកាចគ្មានកង្វល់ ។
ចិត្តគំនិតនៃជនទុច្ចរិត     រមែងតែងគិតដោយល្ងិតល្ងង់
ស្រេចតែចិត្តគិតគ្មានអំពល់     គ្មានយោគយល់អ្នកណាឡើយ ។
ចិត្តគំនិតនៃជនទុច្ចរិត     ជាជនខ្លាំងពិតលើជនខ្សោយ
ទើបហ៊ានប្រមាថធ្វើព្រងើយ     វាយសំពងហើយដាក់គុកទៀត ។
ចិត្តគំនិតនៃជនទុច្ចរិត     តែងតែដេកគិតរកល្បិចស្មៀត
ធ្វើទុក្ខចាក់រុកហ៊ានពិឃាត     មិនឱ្យចេញឃ្លាតពីអំណាច ។
ចិត្តគំនិតនៃជនទុច្ចរិត     រំលោភលើសិទ្ធិដោយគ្មានខ្លាច
លើជនស្លូតត្រង់ចិត្តអង់អាច     ឱ្យបាត់បង់ប្រាជ្ញវិនាសូន្យ ។
ចិត្តគំនិតនៃជនទុច្ចរិត     តែងតែប្រព្រឹត្តខុសផ្ទួនៗ
ធ្វើបាបខ្លាំងណាស់មិនប្រែខ្លួន     ចចេសពេញខ្លួនព្រះលែងប្រោស ។
ជននេះត្រូវតែបោះចោលទៅ     ក្នុងបឹងភ្លើងជ្រៅក្តៅឆេះសុស
រលាយបាត់សាច់ឆ្អឹងទាំងអស់     ព្រលឹងជាប់ទោសនៅអស់កល្ប ។

២-ចិត្តគំនិតនៃជនទុច្ចរិត     បានស្តាប់បណ្ឌិតប្រៀនពន្យល់
ឱ្យមានចិត្តល្អត្រូវសែនសល់     នាំចិត្តទៅដល់ឋានសួគ៌ថ្លៃ ។
ចិត្តគំនិតនៃជនទុច្ចរិត     រមែងតែងតែគិតជលតម្លៃ
កិត្តិយសកេរឈ្មោះជនដទៃ     ឱ្យល្អពេកក្រៃពេញជាមនុស្ស ។
ចិត្តគំនិតនៃជនទុច្ចរិត     តែងតែផ្តោតចិត្តដោយត្រង់ស្មោះ
តាំងចិត្តល្អជួយសង្គ្រោះ     ឱ្យបានរួចរស់មានសិទ្ធិ ។
ចិត្តគំនិតនៃជនទុច្ចរិត     មានភាពស្នេហ៍សិទ្ធមានគតិ
ទឹកចិត្តទៀតត្រង់សុទិដ្ឋិ     ចិត្តបរិសុទ្ធពិតតាមប្រាជ្ញព្រឹទ្ធ ។
ចង់តែធ្វើល្អជួយមូលមិត្ត     គ្រប់គ្នាជួបជិតស្និទ្ធគ្រួសារ
ចិត្តគំនិតនៃជនទុច្ចរិត     ចង់បានការពិតពេញលក្ខណា
ក្នុងភាពជាមនុស្សមានប្រាជ្ញា     ដោះស្រាយបញ្ហាបានជោគជ័យ ។
ចិត្តគំនិតនៃជនទុច្ចរិត     ព្រះតែងអាណិតហើយកែច្នៃ
សាងឱ្យបានស្អាតយ៉ាងប្រពៃ     ជីវិតថ្លាថ្លៃកូនសួនភ្ញា ។
ជននេះត្រូវព្រះប្រទានពរ     យ៉ាងពេញបរិបូរ៍គ្រប់វេលា
ព្រះអង្គនាំទៅដល់សួគ៌ា     ជាឋានសុខាអស់កល្បអើយ ។

## តមកទំព័រទី ១០ លោក កឹម សុខា និងលោក ស ខេង...

គណបក្សសង្គ្រោះជាតិបានចោទប្រកាន់ ម្តង ហើយម្តងទៀតថា តុលាការក្នុងប្រទេសកម្ពុជាពុករលួយនិងស្ថិតក្រោមឥទ្ធិពលរបស់គណបក្សប្រជាជនកម្ពុជា។

លោក អេង ឆៃអ៊ាង ក៏បានថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មានដែរថា វាច្បាស់ណាស់ថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិប្រាំពីររូបដែលបានជាប់ពន្ធនាគារប៉ុន្មានថ្ងៃចន្លោះការតវ៉ាថ្ងៃទី១៥ ខែកក្កដា និងកិច្ចព្រមព្រៀងថ្ងៃទី២២ កក្កដាឆ្នាំ មុនពីបទដឹកនាំ "កុបកម្ម"នោះ នឹងនៅតែមានសុវត្ថិភាពដោយសារតែពួកគាត់មានអភ័យឯកសិទ្ធិតំណាងរាស្ត្រការពារខ្លួនពីការផ្តន្ទាទោស។

លោកបានលើកឡើងបន្តថា "សម្រាប់តំណាងរាស្ត្រទាំងប្រាំពីររូប ដោយសារតែពួកគាត់មានអភ័យឯកសិទ្ធិ ដូច្នេះតុលាការមិនអាចឃុំឃាំង ឬចាប់ខ្លួនពួកគាត់បានទេ"។

លោក ហ៊ុន សែន បានគំរាមតំណាងរាស្ត្រទាំងនេះម្តងហើយម្តងទៀតថា នឹងត្រូវប្រឈមសវនាការជំនុំជម្រះទោស ប៉ុន្តែរហូតមកទល់ពេលនេះសាលាដំបូងរាជធានីភ្នំពេញមិនទាន់បានចេញដីកាកោះហៅតំណាងរាស្ត្រណាម្នាក់មកសាកសួរនៅឡើយទេ ចាប់តាំងពីលោកស្រី មូរ សុខហួរ ដែលបានដឹកនាំការតវ៉ាកាលពីឆ្នាំមុន បានរក្សាភាពស្ងាត់ស្ងៀមអំឡុងការសាកសួរលោកស្រី កាលពីថ្ងៃទី១១ ខែឧសភាមក។

ដោយឡែក លោក សក់ សេដ្ឋា បានមានប្រសាសន៍ថា លោក ស ខេង និងលោក កឹម សុខា បានពិភាក្សាគ្នាអំពីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលដ៏ចម្រូងចម្រាសដែលត្រូវបានអនុម័ត កាលពីពេលថ្មីៗនេះ ដែលបច្ចុប្បន្នធម្មនុញ្ញភាពនៃច្បាប់នេះកំពុងត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយក្រុមប្រឹក្សាធម្មនុញ្ញ។

លោកបានលើកឡើងទៀតថា រដ្ឋាភិបាលមិនអាចអន្តរាគមន៍បានឡើយនៅក្នុងដំណើរការនីតិវិធីនោះ ប៉ុន្តែថា នៅពេលច្បាប់នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាធម្មនុញ្ញ និងឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រនរោត្តម សីហមុនី គណបក្សប្រជាជនកម្ពុជាប្រហែលជានឹងពិភាក្សាចរចាជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីធ្វើវិសោធនកម្ម។

លោកបានបញ្ជាក់ថា "នីតិវិធីនេះនៅតែបន្តដំណើរការ ប៉ុន្តែនៅពេលអនុវត្តប្រសិនណា បើមានការប៉ះពាល់ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋគណបក្សទាំងពីរបានព្រមព្រៀងគ្នាថា នឹងពិនិត្យមើលលើបញ្ហាដែលមានផលប៉ះពាល់ទាំងនោះ ហើយនឹងធ្វើវិសោធនកម"៕

**សុខុម**



"អត្ថបទទស្សនៈ ថវិការគ្រួសារជាអ្វី?"

# និយាយពីក្រ និងមាន

## ភាគ៤ - ការពារសេដ្ឋកិច្ចគ្រួសារ

**ដោយ ពិន សំខុន**



ពិន សំខុន

សន្សំឆ្នាំទី ១០-១០.០០០៛ បានការប្រាក់៨ភាគរយ =១៨.០០០៛ធានាគារ"ខ": លុយដើមរស់ - ការប្រាក់រស់ សន្សំឆ្នាំទី១-១០.០០០៛ បានការប្រាក់៨ភាគរយ=១០.៨០០៛

សន្សំឆ្នាំទី២-១០.៨០០៛ បានការប្រាក់៨ភាគរយ=១១.៦៦៤៛

សន្សំឆ្នាំទី១-១១.៦៦៤៛ បានការប្រាក់៨ភាគរយ=១២.៥៩៧៛

សន្សំឆ្នាំទី១០ បានការប្រាក់៨ភាគរយ =២១.៥៨៩៛

ក្នុងចំនួនលុយ១ដុំ(សម្រាប់អ្នកដែលមានលទ្ធភាព)ដែលយើងដាក់សន្សំឃើញថា បានលទ្ធផលខុសគ្នាគួរកត់សំគាល់។ ដូចគ្នានឹងឧទាហរណ៍នេះ គេក៏អាចសន្សំក្នុងចំនួនប្រាក់១០០-២០០-៣០០ជារៀងរាល់ខែ(សម្រាប់អ្នកដែលរស់នឹងប្រាក់ខែ) បានដែរ។

បង់ពន្ធជូនរដ្ឋនៅស.រ.អានេះ ឧទាហរណ៍ខាងលើ បើលុយកើនពីការប្រាក់ក្រសួងពន្ធដារគេចាត់ថាជាប្រាក់ចំណេញ ដូច្នេះក្នុងលុយកើននោះ គេកាត់យករួចជាស្រេចចំនួនប្រមាណ២០ភាគរយ។ ដូចនេះ មុននឹងប្តើមសន្សំ គេត្រូវរកក្រុមហ៊ុនណាជាធានាគារមានកម្មវិធីដែលគេមិនកាត់លុយលើប្រាក់ចំណេញនោះ។

យើងបានលើកយកពាក្យអ្នកមានលុយលានដុល្លាម្នាក់មករំលឹកថា "កុំសន្សំអ្វីដែលសល់ពីចាយ គឺចាយអ្វីដែលសល់ពីសន្សំ"។ បើអ្នកធ្វើតាមបាន គឺជាការប្តេជ្ញាចិត្តដ៏ច្បាស់លាស់មួយ ហើយផ្តើមនូវគំនិតព្យាយាមអនុវត្តសម្តីនេះឱ្យបានខ្ជាប់ខ្ជួនជារៀនរហូតទៅមិនថា "មានហូប ឬអត់ឃ្លានឱនោះទេ ជាពិសេសសម្រាប់អ្នកក្រីក្រមិនគួរឱ្យមានចន្លោះសម្រាប់ការគិតរាយមាយបានទេ ដូចជាភាពហ៊ឺហា ខ្លាចខ្មាសគេ ទៅធ្វើបុណ្យដែលទាំងអស់នោះត្រូវរាប់ជាប្រាក់ចំណាយដែលមិនចាំបាច់ខុសគ្នាពីចំណាយដែលយើងអធិប្បាយកាលពីលេខមុន។

សន្សំ គឺជាករណី កិច្ចចាំបាច់សម្រាប់កសាងអនាគត គឺមានពាក្យ "ព្យាយាម"នៅក្នុងនោះ តែក៏មិនត្រូវធ្វើឱ្យហួស ហេតុ រហូតដល់អាចគ្រោះថ្នាក់ដល់សុខភាព ឬដល់សន្តិសុខ ឬក៏ដល់បរិយាកាសសង្គមនោះ ទេ។ ជាទូទៅគួរចាប់



យកទូលេខ១ភាគ៤នៃប្រាក់ចំណូលយកទៅវ៉ាយចំណែកឱ្យទៅជាសន្សំ ដូចជា:

**១.**ដកប្រាក់៥០០ដុល្លាទៅសន្សំក្នុងចំណោមប្រាក់ចូលក្នុងផ្ទះ $២០០០

**២.**$៥០០នោះ អាចបែកចែកជាប្រាក់សន្សំ :

**ក.**ទុកសម្រាប់សង្គ្រោះបន្ទាន់ $១០០(ដកចាយបានតែនៅពេលឈឺធ្ងន់)

**ខ.**សន្សំទុកចែកកូន$២០០(ដាក់ក្នុងធានាគារដែលមានការប្រាក់ឱ្យគេដកយកទៅទុកឱ្យ១០ ឬ២០ឆ្នាំ ជាប្រចាំរៀងរាល់ខែមិនឱ្យដាច់)

**គ.**សន្សំទុកធ្វើដំណើរ$១០០(ធ្វើដំណើរ១ឆ្នាំ ឬ២ឬ៣ឆ្នាំម្តង)

**ឃ.**សន្សំទុកប្តូរខោអាវ $១០០ ។

ក្មេងសម័យថ្មីសាលាជួយបង្រៀនឱ្យមាន




របៀបរបបនេះ ហើយចាស់ៗក៏គួរតែលើកទឹកចិត្តឱ្យគ្នាមានទម្លាប់នេះជាមួយគ្នាឡើងដែរ។ នេះជាសំណាងថ្មីរបស់យើងដែលមកដល់ប្រទេស



អាមេរិកាំងនេះ គេមិនទុកឱ្យយើងស្លាប់ដោយភាពក្រីក្រនោះទេ។

**តទៅលេខក្រោយ**

B&M DISPOSAL 978-569-6062

ក្រុមហ៊ុនដឹកជញ្ជូនសំរាម ប៊ីអឹម



កុងទីន័រដាក់សម្រាម 30 YARD CONTAINER
រហូតដល់ ៤ តោន $549

កុងទីន័រដាក់សម្រាម 20 YARD CONTAINER
រហូតដល់ ៣ តោន $449

កុងទីន័រដាក់សម្រាម 15 YARD CONTAINER
រហូតដល់ ២ តោន $349

*សូមបង់ថែម $100 ក្នុង ១០០០ ផោនបន្ថែម។ អនុញ្ញាតឱ្យដាក់បន្ថែមលើសទម្ងន់អតិបរមានៅលើកុងទីន័រណាមួយខាងលើបាន។

សូមទាក់ទងឈ្មោះ ប៊ុន ឥឡូវនេះ!
មានផ្តល់សេវាជូនដល់ហាងទំនិញ និងតាមផ្ទះ




BUSINESS – RESIDENTIAL

1687 Middlesex St. Lowell, MA 01851

CAll BUN 978-569-6062

**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

**ផ្សាយពាណិជ្ជកម្ម Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

ផ្សារពាណិជ្ជកម្ម ហ្វីឡាដែលហ្វៀ SomrithSom

**អ្នកនិពន្ធ Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស Contributed Writers:**

Kim Phien, Richard Howe ,Jr. ,Tooch Van

យកព័តមាន Chhan Yon (504) 912 2660

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

នាយករដ្ឋបាល Office Manager **978-677-7163**

Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the East Coast of United States. The newspaper prints 32 pages an issue - all in color, premium 35 pound stocks paper. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. Found in 2007 by a respectable Cambodian Journalist, Roger Samkhon Pin, the former President of Cambodian Journalist Association of Cambodia (1994-1997), the Director of Radio Free Asia, Cambodian Services in Washington D.C (1998-2003), and the founder and broadcaster of Cambodian-American news through five Radio Stations around the U.S (2004-2008).

## Publication Frequency

24 times a year.

## General Information

**Circulations:** 15,000 copies per month.

**Distributions:**

- 70+ locations in Lowell, MA (5,000 copies per issues)

**2015 Remaining Prints**

- September 4th & 18th
- October 9th & 23rd
- November 6th & 20th
- December 4th & 18th

* all ad materials are due one due one week prior to the publishing date.

## Advertising Rates

| Ads Size | 1 issue | 3 months 5% off | 6 months 7.5% off | 12 months 10% off |
|---|---|---|---|---|
| Full Page Color | 460 | 874/month | 851/month | 828/month |
| ½ page (color) | 310 | 589/month | 573.50/month | 558/month |
| ¼ page (color | 165 | 313.50/month | 305.25/month | 297/month |
| 1/8 page color) | 90 | 171/month | 166.50/month | 162/month |


KHMERPOST USA August 10th - 23rd, 2015 Page.1

KhmerPost USA

E-mail: info@khmerpost.us / Hotline news: 978-942-1641

CMAA Hosted a memorable fashion show

Law Office of Thomas Stylianos Jr.

287 Appleton St. Lowell MA 01852

- Immigration
- Auto Crash
- Divorce

978-459-5000 or 800-308-3766

CENTURY PHARMACY & OPTICAL

937 Gorham St Lowell, MA, 01852

978-455-6554 / 978-455-9476

REMEDIUM PHARMACY

FREE daily delivery | Blisterpack Packaging | Compounding Medication

Tel: 978-251-7070 | Fax: 978-251-7071

**Back and Front Page ad spaces are available.**

**Contact: Soben Pin, Managing Partner**

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852

**Tel:** 978.677.7163. **Cell:** 978. 656.8141. **Fax:** 978.677.7092

Email: sobenpin@khmerpost.us

www.khmerpost.us

Schedules and Rates revision and effective September 2015 – August 2016

# កុំមើលងាយ! ផ្លែក្រខុប និងស្លឹកវា មានអត្ថប្រយោជន៍ហួសស្មាន



●●●បើនិយាយពីផ្លែក្រខុបប្រជាជនខ្មែរពិតជាស្គាល់វាជាមិនខាន ព្រោះជាផ្លែឈើមួយប្រភេទដែលមានរសជាតិផ្អែមឆ្ងាញ់ និងងាយដុះស្ទើរគ្រប់កន្លែង។ ប៉ុន្តែមនុស្សមួយចំនួនប្រហែលជាមិនដឹងទេថា ក្រខុបនេះមានអត្ថប្រយោជន៍ច្រើនចំពោះសុខភាពប៉ុណ្ណោទេ។ បើចង់ដឹងយើងនឹងបង្ហាញជូននូវអត្ថប្រយោជន៍ផ្លែក្រខុបនេះ:

**១.ប្រឆាំងបាក់តេរី**

ក្រខុបមានសមាសធាតុជាច្រើនដែលអាចការពារបាក់តេរី និងជួយព្យាបាលជំងឺខាន់ស្លាក់មេរោគ និងបាក់តេរីផ្សេងទៀត។

**២.ព្យាបាលឈឺតាមសន្លាក់ឆ្អឹង**

ច្រើនសតវត្សមកហើយមានប្រទេសមួយចំនួនធំបានប្រើផ្លែក្រខុប ដើម្បីបញ្ឈប់ការឈឺចាប់ដែលផ្សារភ្ជាប់ជាមួយនឹងរោគប្រគ្រីវក៏មាន។ ការទទួលទានក្រខុបមួយថ្ងៃ៩ទៅ១២ផ្លែបីដងក្នុងមួយថ្ងៃជាការព្យាបាលការឈឺចាប់បានយ៉ាងល្អ។

**៣.ជំងឺទឹកនោមផ្អែម**

ក្រខុបជាផ្លែឈើមានជាតិស្ករតិចដែលអាចជួយបន្ថយជាតិស្ករក្នុងឈាមបានផងដែរ ដូច្នេះធ្វើឱ្យវាជាផ្លែឈើដ៏ល្អសម្រាប់អ្នកមានជំងឺទឹកនោមផ្អែម។

**៤.សម្បូរវីតាមីន C**

ផ្លែឈើនេះជាប្រភពដ៏ល្អនៃវីតាមីន C មានសារធាតុប្រឆាំងអុកស៊ីតកម្មដ៏ខ្លាំងមួយដែលអាចជួយប្រយុទ្ធប្រឆាំងនឹងជំងឺផ្តាសាយ និងសូម្បីតែជំងឺសរសៃឈាមបេះដូង។

**៥.ទប់ស្កាត់ការឈឺចាប់**

ស្លឹកវាគឺអាចផ្សំធ្វើជាតែដើម្បីទប់ស្កាត់ការឈឺចាប់។

**៦.ការពារសរសៃឈាមបេះដូង**

ស្លឹករបស់វាដែលផ្សំធ្វើតែនោះ មិនត្រឹមតែទប់ស្កាត់ការឈឺចាប់ប៉ុណ្ណោះទេ ថែមទាំងអាចការពារជំងឺគាំងបេះដូង ព្រោះស្លឹករុក្ខជាតិនោះមានផ្ទុកសារធាតុប្រឆាំងអុកស៊ីតកម្មដែលរារាំងការរលាកដែលនាំឱ្យងាប់ជាលិកាសាច់ដុំបេះដូង។

**៧.ព្យាបាលជំងឺមហារីក**

ការស្រាវជ្រាវបានឱ្យដឹងថា ស្លឹករបស់វាត្រូវបានគេសិក្សា និងបង្ហាញសមត្ថភាពប្រឆាំងដ៏ធំ ហើយវាអាចនឹងត្រូវគេប្រើយ៉ាងទូលំទូលាយនាពេលអនាគតសម្រាប់ព្យាបាលជំងឺមហារីក។

**៨.ប្រឆាំងការរលាក**

តែដែលមានផ្សំពីស្លឹកក្រខុបគឺអាចព្យាបាលការរលាកហើម និងសម្រាប់ទប់ស្កាត់ជំងឺគ្រុនបានទៀតផង។

**៩.បន្ថយសំពាធឈាម**

តែធ្វើពីស្លឹកក្រខុបអាចបញ្ចុះសំពាធឈាមព្រោះវាមានសារធាតុនីទ្រិចអុកស៊ីតដែលអាចបន្ធូរសរសៃឈាម ដូច្នេះប្រសិនបើសំពាធឈាមឡើងគឺទទួលទានតែនេះនឹងបញ្ចុះមកវិញបាន។

**១០.ព្យាបាលអាការឈឺក្បាល**

ការបរិភោគផ្លែឈើប្រភេទនេះ ឬផឹកតែធ្វើពីស្លឹកវាគឺជាឱសថស័ក្តិសិទ្ធិនឹងកម្ចាត់អាការឈឺក្បាលបានភ្លាម។

**១១.ផ្ទុកសារធាតុចិញ្ចឹមច្រើន**

ក្រខុបមានផ្ទុកជាតិទឹក ជាតិស្ករ ប្រូតេអ៊ីនសម្រាប់ធ្វើឱ្យសាច់ដុំរឹងមាំ។ ចំណែកកាល់ស្យូម និងផូស្វាតសម្រាប់ឆ្អឹងរឹងមាំជាតិដែកសម្រាប់អ្នកមានជំងឺស្លេកស្លាំង និងវីតាមីនពធ្វើឱ្យមានអារម្មណ៍ល្អ។

# ចំណាយថោកជាង១ដុល្លារ ដើម្បីសំអាតក្រលៀនរបស់អ្នក

ជាច្រើនឆ្នាំមកហើយដែលក្រលៀនច្រោះឈាមហើយយកចេញនៅសារធាតុអំបិល សារធាតុពុល និងសារធាតុដែលមិនត្រូវការចេញពីរាងកាយយើង។ ហេតុនេះវាត្រូវការពេលដើម្បីលាងសំអាត។ តើយើងត្រូវធ្វើរបៀបណា? ការលាងសំអាតក្រលៀនគឺមិនពិបាកទេ ហើយចំណាយអស់តិចបំផុត ដោយច្រោះយកទឹក និងយកទឹកដែលច្រោះបានទៅច្រកក្នុងដបស្អាតរួចដាក់វាក្លាហ្សេក្នុងទូរទឹកកកអោយត្រជាក់។

សូមពិសារទឹកនេះ មួយកែវជារៀងរាល់ថ្ងៃនោះ អ្នកនឹងកត់សំគាល់ឃើញថាជាតិអំបិល និងជាតិពុលដែលយើងទទួលទាននឹងចេញពីរាងកាយ



គ្រាន់តែលោកអ្នកទិញវ៉ាន់ស៊ុយ មួយ បាច់ ហើយលាងវាអោយស្អាត។ បន្ទាប់មកកាត់វាជាកង់ៗតូចៗ ហើយដាក់វាក្នុងឆ្នាំងដាំជាមួយទឹករយៈពេល ១០នាទី ហើយទុកវាអោយត្រជាក់យកវាទៅយើងតាមទឹកនោម។ ហើយអ្នកនឹងមានអារម្មណ៍ថា ស្រួលខ្លួនប្លែកពីធម្មតា។ វ៉ាន់ស៊ុយត្រូវបានគេទទួលស្គាល់ថាជាឱសថធម្មជាតិដែលជួយព្យាបាល និងលាងសំអាតក្រលៀន៕

HIFE COLLEGE PLANNING PROGRAM



"PROVIDING FAMILIES WITH COLLEGE PLANNING SOLUTIONS."

Who We Are ...

The Heartland Institute of Financial Education is a national 501(c)(3) non-profit organization whose mission is to promote financial literacy across America. Our mission begins with our HIFE College Planning Program.

It is the goal of the Heartland Institute of Financial Education to help young Americans obtain a college education.

What We Do ...

Help families offset the high cost of college by utilizing proven strategies to help reduce a family's "out-of-pocket" costs...

How We Do It ...

Based on a family's specific financial situation, The Heartland Institute of Financial Education determines strategies that will reduce the family's "Expected Family Contribution" (EFC), thereby qualifying the student for "Need-Based" monies from both federal and state resources, as well as the college's own resources and private resources.

What Do We Provide ...

The Heartland Institute of Financial Education provides detailed analysis and strategies that help "mitigate" the high cost of college. Each client/family is assigned a "Coach" who works directly with the student and parents, assisting them with the college planning, funding and admissions process.

Sunny Su & Laurent Lheritier
Certified College Consultants
Phone: (617) 201-7065
Email: suyusunny@yahoo.com

www.hife-usa.org

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE 978-596-1111

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយ ដែលផ្ដល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

## មណ្ឌលផ្ដល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្ដៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips



សូមហៅលេខទូរស័ព្ទ (978) 596-1111



# Red Rose RESTAURANT

ភោជនីយដ្ឋាន កុលាបក្រហម

ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm












* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400




# Khmer Post Subscription form

Khmer Post subscription is $10 for 1month -$30 for 3 month -
$50 for 6 months and $100 for12 months
The price is only for mailing - We send your personal mail via Post office.

យើងទទួលយកតែ"ម៉ានីអ័រឌឺ"តែប៉ុណ្ណោះ -We accept Money order -Check

អាស័យដ្ឋាន Khmer Post address :45 Merrimack St.Suite 218A Lowell, MA 01852

ទូរស័ព្ទ Phone : off.978 677 7163 -Soben's Cell.978-656 8141
- Roger Cell. 978 - 942 1641

<<www.Khmerpostusa.us>> publication is 2 issues per month

## ប័ណ្ណបញ្ជាទិញកាសែត"ខ្មែរផុសស.រ.អា"
## Khmer Post subscription order

ឈ្មោះ - My name.........................................................................

អាស័យដ្ឋាន -Address.....................................................................

..........................................................................................

ខ្ញុំចង់ជាវកាសែតខ្មែរផុសស.រ.អា...................ខែ.........តម្លៃជាវ..............ដុល្លារ

I'd like to subscribe Khmer Post USA for ...........
Month(s)-Subscrition price $.......................

# ទើបបើកថ្មី ! សាលាខ្មែរបង្រៀនថែសម្ផស្ស និងក្រចកនៅឡូវែល




120 Cross St. Lowell, MA 01854 (Formerly CMAA Building)
www.lowellacademy.net, **978-459-5300**



សាលាខ្មែរដំបូងបង្អស់នៅទីក្រុងឡូវែល ចាប់បើកបង្រៀនជំនាញថែសម្ផស្ស និងធ្វើក្រចកដល់បងប្អូនខ្មែរ ដោយគ្រូខ្មែរជាភាសាខ្មែរ
យើងមានសេវាផ្សេងៗដូចជា •ដឹកជញ្ជូនទៅមក •ជួយរកការងារឱ្យធ្វើ •ណែនាំឱ្យប្រឡងជាប់
ថ្នាក់ផ្តើមថ្ងៃទី ៣១ សីហា ២០១៥ (បីវេន: ថ្ងៃ, យប់, ចុងសប្តាហ៍)

- Class Starts August 31st, 2015 **(Day, Nights, and Weekends)**
- Services : ESL Class • Transportation •Job Placements • Tutoring for Exams

## សូមទាក់ទងដើម្បីចុះឈ្មោះថ្ងៃនេះ !
## 978-459-5300

ដើម្បីព័ត៌មានបន្ថែមសូមទាក់ទងលោកនាយកគ្រប់គ្រង : សេង ហាប់រឿន តាមលេខទូរស័ព្ទ : (978) 888-8099